# ព្រឹទ្ធសភា

# SENATE MAGAZINE

ទស្សនាវដ្ដីប្រចាំខែ



លេខ ២៦៦ ឆ្នាំទី២២

ពុទ្ធសករាជ ២៥៦៦ គ្រិស្តសករាជ ២០២២

Issue 266 Volume 22

Before Christ 2566 Common Era 2022

# មាតិកា



## សកម្មភាពថ្នាក់ដឹកនាំ


- សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង ចូលជួបសម្តែងការគួរសម...................................... ១
- ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤.......................................................................៣
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី៩ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៣..........................៤
- ព្រឹទ្ធសភារៀបចំវេទិកាពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅខេត្តសៀមរាប ......... ៧
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញសម្ពោធសមិទ្ធផលនានា នៅវត្តតាំងក្រសាំងខាងជើង....................... ១០
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញសម្ពោធសមិទ្ធផលនានា និងស្រោចស្រពសុគន្ធវារីប្រគេនព្រះចៅអធិការវត្តព្រែកជ្រៃ...................................................................................................... ១២
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសហការរៀបចំសិក្ខាសាលាស្តីពី “កម្ពុជា-ចិន រួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩”.............................................................................................. ១៥
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ............................................................ ១៨




## សកម្មភាពគណៈកម្មការ


- គណៈកម្មការទី១ព្រឹទ្ធសភា ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ជួបពិភាក្សាលើសំណើរបស់ជនជាតិដើមភាគតិច ........................................................ ១៩
- គណៈកម្មការទី៥ព្រឹទ្ធសភាចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង.............................. ២១
- គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តចំនួន៤ .......................................................................................................២៤
- គណៈកម្មការទី១០ព្រឹទ្ធសភានាំយកអំណោយសម្តេចប្រធានព្រឹទ្ធសភាប្រគល់ជូនរដ្ឋបាលខេត្តពោធិ៍សាត់ និងមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ .....................................................................................២៦
- ក្រុមមិត្តភាពសភាកម្ពុជា ជាមួយរដ្ឋសភាវៀតណាម អញ្ជើញបំពេញទស្សនកិច្ចការងារ នៅប្រទេសវៀតណាម .....២៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ...................................................................... ៣១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ................................................................ ៣៥
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨..................................................... ៣៦
- ការងារទទួលពាក្យបណ្តឹង........................................................................................................៤២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ............................................................................ ៤៣




## សកម្មភាពអគ្គលេខាធិការដ្ឋាន


- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២២........................................................ ៤៧
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះអនុស្សរណៈយោគយល់គ្នាជាមួយវិទ្យាស្ថានស្រាវជ្រាវ KING PRAJADHIPOK..........................................................៤៨
- ថ្នាក់ដឹកនាំ គ្រប់គ្រងអង្គភាពចំណុះអ.ពស ត្រូវបានពង្រឹងសមត្ថភាពលើជំនាញការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ....... ៤៩
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ .................................................... ៥០



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លឹម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម ជួន ណា

ឯកឧត្តម គឹម ពិសិដ្ឋ

លោក ជួន សុខធី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោកស្រី សុខ សុជាតា


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង (APF)។*

*ក្របក្រោយ ៖ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ អញ្ជើញកាត់ខ្សែបូសម្ពោធសមិទ្ធផលនានា ក្នុងវត្តព្រែកជ្រៃ (ហៅវត្តជ្រោយបទុម) ស្ថិតក្នុងភូមិបារគូ សង្កាត់ផ្កាដ្កោ ខណ្ឌផ្កាដ្កោ រាជធានីភ្នំពេញ៕*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# សម្តេចប្រធានព្រឹទ្ធសភាអនុញ្ញាតឱ្យគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង ចូលជួបសម្តែងការគួរសម



*ឯកឧត្តម Christophe-André Frassa និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នាព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៩:៥០នាទី សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង (APF) ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង (APF) បំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយ និងស្វាគមន៍ចំពោះឯកឧត្តម Christophe-André Frassa និងគណៈប្រតិភូដែលបានអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា។ តាមរយៈដំណើរទស្សនកិច្ចរបស់ឯកឧត្តម និងគណៈប្រតិភូនាពេលនេះ បានរួមចំណែកក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងសភានិយាយភាសាបាំង (APF) ជាមួយនឹងសភាកម្ពុជា។

ក្នុងឱកាសនោះ ឯកឧត្តម Christophe-André Frassa បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភា អំពីគោលបំណងនៃដំណើរទស្សនកិច្ចការងាររបស់គណៈប្រតិភូ ដើម្បីវាយតម្លៃអំពីការវិវឌ្ឍស្ថានការណ៍នយោបាយនៅព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌសភាប្រើភាសាបារាំង (APF)។ ជាមួយគ្នានោះ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងប្រទេសកម្ពុជា ជាមួយនឹងបណ្តាប្រទេសប្រើភាសាបារាំង។

ឯកឧត្តម Christophe-André Frassa បានជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភាជ្រាបថា បច្ចុប្បន្នក្នុងក្របខ័ណ្ឌសភាប្រើភាសាបារាំង (APF) មានលេខាធិការដ្ឋានមួយដើម្បីពិនិត្យអំពីលក្ខន្តិកៈរបស់សភានិយាយភាសាបារាំងទាក់ទងនឹងបញ្ញត្តិ និងការពិនិត្យ តាមដានឃ្លាំមើលអំពីបញ្ហាប្រជាធិបតេយ្យនៅបណ្តាប្រទេសជាសមាជិក។

ក្នុងឱកាសនោះដែរ សម្តេចប្រធានព្រឹទ្ធសភាបានរំលឹក





*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*



*ទិដ្ឋភាពក្នុងពិធីជួបសម្តែងការគួរសម*

ថា ចាប់តាំងពីឆ្នាំ១៩៩៣ ប្រទេសកម្ពុជាអនុវត្តន៍ការបោះឆ្នោតយ៉ាងទៀងទាត់តាមពេលវេលាកំណត់ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ដោយមានគណបក្សនយោបាយចំនួន ១៧ចូលរួម ហើយមានគណបក្សចំនួន៩ បានទទួលអាសនៈនៅថ្នាក់ឃុំ-សង្កាត់។ ការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង គ្មានអំពើហិង្សាដែលទាំងអស់គ្នាទទួលយកបាន និងមានអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ចូលរួមគ្រប់ដំណាក់កាលមុនបោះឆ្នោត អំឡុងពេលបោះឆ្នោត និងក្រោយការបោះឆ្នោត។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា សភាកម្ពុជាបានដើរតួនាទីដ៏សកម្មក្នុងវេទិកាសភានិយាយភាសាបារាំងនៅក្នុងតំបន់ និងសកលលោក។ កិច្ចសហប្រតិបត្តិការល្អរវាងសភាកម្ពុជា និងហ្វ្រង់កូហ្វូនី បានប្រព្រឹត្តទៅដោយរលូនលើគ្រប់យន្តការទាំងអស់នៃAPF និងកិច្ចសហប្រតិបត្តិការបច្ចេកទេស។ សភាកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់សារៈសំខាន់ធ្វើកិច្ចសហប្រតិបត្តិការដោយបើកចំហជាមួយនឹងមិត្តភក្តិបរទេស និងដៃគូអន្តរជាតិទាំងអស់ដែលចង់ឈ្វេងយល់អំពីស្ថានភាពនយោបាយ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការបញ្ចេញមតិនៅកម្ពុជា។ ជាក់ស្តែង សភា និងរាជរដ្ឋាភិបាលបានសហការដ៏ជិតស្និទ្ធជាមួយនឹងអ្នករាយការណ៍ពិសេសស្តីពី សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងគណៈកម្មការសិទ្ធិមនុស្ស ព្រមទាំងសមាជិកសភារបស់ IPU នាពេលកន្លងទៅនៅកម្ពុជា។

ជាមួយគ្នានោះ សម្តេចប្រធានព្រឹទ្ធសភាបានជម្រាបឯកឧត្តម Christophe-André Frassa ជ្រាបថា លំហប្រជាធិបតេយ្យ សិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិធ្វើនយោបាយ សិទ្ធិក្នុងការជួបជុំរបស់ប្រជាពលរដ្ឋ គណបក្សនយោបាយ អង្គការសារព័ត៌មាន អង្គការសង្គមស៊ីវិល បាននឹងកំពុងដំណើរការដោយសេរី គ្មានការរើសអើង គ្មានការគំរាមកំហែង។

សម្តេចប្រធានព្រឹទ្ធសភាបានជូនពរឯកឧត្តម និងគណៈប្រតិភូឱ្យមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវភាពរីករាយក្នុងឱកាសស្នាក់នៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*សម្តេចប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម Christophe-André Frassa*

# ព្រឹទ្ធសភាប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃពុធ ទី៧ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ រួមមាន៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។**

**២- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។**

**៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើ ៖**

**១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន**

**២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក)នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ**

**៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។**

**៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃព្រហស្បតិ៍ ទី៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំពេញអង្គលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ទាំងបីខាងលើ។

(អត្ថបទ៖ នុត សច្ចៈ រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី៩ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ចំនួន៣



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ដឹកនាំបន្ត សម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៧រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៣ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។**

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានអនុវត្តក្នុងបរិការណ៍ នៃវិបត្តិជំងឺកូវីដ-១៩ ដើម្បីតម្រង់ការប្រើប្រាស់ធនធានសម្រាប់ទ្រទ្រង់ដល់និរន្តរភាព នៃប្រតិបត្តិការរបស់រដ្ឋ និងសម្រាប់ការរក្សាលំនឹងសង្គម-សេដ្ឋកិច្ចកម្ពុជា និងជីវភាពរបស់ប្រជាជន ព្រមទាំងស្ដារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច ក៏ដូចជាដើម្បីសម្រេចនូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។

ម្យ៉ាងទៀត ថវិកាឆ្នាំ២០២១ត្រូវបានសន្និដ្ឋានថា ជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព ដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ហើយត្រូវបានប្រសិទ្ធនាមថា ជា «ថវិកាប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គម សេដ្ឋកិច្ច និងជីវភាពប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិ នៃជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន»។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន៣ជំពូក និង២២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមជាលើកដំបូងចំនួន៨៨សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាព



*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤*

ទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។



*ឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត ជា ជេដ្ឋ ឡើងអានរបាយការណ៍*

**របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដី-ព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។**

សេចក្ដីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើង នៅក្នុងបរិ-ការណ៍ដែលសេដ្ឋកិច្ចកម្ពុជាកំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតី បន្ទាប់ពីរាជរដ្ឋាភិបាលទទួលបានជោគ-ជ័យដ៏ត្រចះត្រចង់ក្នុងការប្រយុទ្ធនឹងការរីករាលដាល នៃជំងឺកូវីដ-១៩ និងក្នុងការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺនេះបានយ៉ាងល្អ ទាំងការការពារសុខភាពសាធារណៈ ការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច និងការធានាទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលអនុញ្ញាតឱ្យកម្ពុជាបើកប្រទេសឡើងវិញ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ និងបានធ្វើឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុក ចាប់ផ្ដើមវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។

ថវិកាឆ្នាំ២០២៣ ត្រូវបានគិតគូរ និងរៀបចំឡើង ដើម្បីតម្រង់ធនធានឆ្ពោះទៅបន្តការពារអាយុជីវិត រក្សាលំនឹងជីវភាព ការងារ និងប្រាក់ចំណូលរបស់ប្រជាជន ព្រមទាំងទ្រទ្រង់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច ពិសេសការបន្តអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយនឹងកូវីដ-១៩ តាមគន្លងប្រក្រតីថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ការធានាដល់ជោគជ័យ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ី-អាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេមឆ្នាំ២០២៣ ក៏ដូចជាការបន្តនិរន្តរភាព នៃប្រតិបត្តិការរបស់រដ្ឋ និងការសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិ-បាល ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣។

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន៥ជំពូក និង១៤មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជាអនុម័តយល់ព្រមជាលើកដំបូងចំនួន៨៩សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៦។



*ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឡើងការពារសេចក្ដីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន៤រូប បានឡើងមានយោបល់រួចមក ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី៣៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដី-ព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើ៖**

**១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន**

**២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក)នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរ-ជាតិ**

**៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។**

សេចក្ដីព្រាងច្បាប់នេះតាក់តែងឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រម



*ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍*

ជាលើកដំបូងចំនួន៨៨សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៦។

ព្រះរាជាណាចក្រកម្ពុជានឹងទទួលបានផលប្រយោជន៍ពីពិធីសារទាំង៣នេះ ដូចខាងក្រោម៖

-កម្ពុជាមានសិទ្ធិក្នុងការចាត់វិធានការសមស្រប ដើម្បីការពារការរំលោភដែនអាកាសរបស់ខ្លួន និងទប់ស្កាត់ការប្រើប្រាស់អាកាសយានក្នុងគោលបំណងមិនស្របនឹងគោលបំណង នៃអនុសញ្ញាសំដៅលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពអាកាសចរណ៍ស៊ីវិលកម្ពុជា។

-ធ្វើឱ្យក្រុមហ៊ុនអាកាសចរណ៍ អ្នកដំណើរតាមផ្លូវអាកាស និងអ្នកវិនិយោគកាន់តែមានជំនឿលើសន្តិសុខ និងសុវត្ថិភាពដែនអាកាសកម្ពុជា ដែលតាមរយៈនេះ កម្ពុជាទាក់ទាញការហោះហើរ និងដឹកជញ្ជូនកាន់តែច្រើនមកកម្ពុជា

-ដើម្បីបង្ហាញពីសុឆន្ទៈ និងកិច្ចសហប្រតិបត្តិការល្អរបស់កម្ពុជាជាមួយនឹងអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) និងដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះកម្ពុជាលើឆាកអន្តរជាតិ និងបើកឱកាសកាន់តែធំសម្រាប់កម្ពុជាក្នុងការចូលរួមដោយផ្ទាល់ទៅក្នុងយន្តការដឹកនាំរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO)

-ដើម្បីជំរុញឱ្យស្ថាប័នដឹកនាំរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) កាន់តែមានប្រសិទ្ធភាព ធានាឱ្យមានសុខសុវត្ថិភាពសម្រាប់ប្រតិបត្តិការហោះហើរ ក្នុងពិភពលោក និងនៅព្រះរាជាណាចក្រកម្ពុជា សំដៅជំរុញកំណើនសេដ្ឋកិច្ច វិនិយោគ ទេសចរណ៍ កំណើនការងារ ការតភ្ជាប់វប្បធម៌រវាងប្រជាជន និងប្រជាជន។



*ឯកឧត្តមបណ្ឌិត ម៉ៅ ហាវណ្ណាល់ ឡើងការពារសេចក្ដីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន២រូប បានឡើងមានយោបល់រួចមក ឯកឧត្តមបណ្ឌិត **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ ទេព មករា រូបភាព៖ ធុន គីមជី)





*សមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តច្បាប់*

# ព្រឹទ្ធសភារៀបចំវេទិកាពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅខេត្តសៀមរាប




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញជាអធិបតីភាពក្នុងពិធីបើកវេទិកា នៅខេត្តសៀមរាប*

នាព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំវេទិកាស្ដីពី ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ក្រោមអធិបតីភាពបើកវេទិការបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៅសណ្ឋាគាររ៉ូយ៉ាល់អង្គររីសត ខេត្តសៀមរាប។

វេទិកានេះរៀបចំដោយក្រុមសមាជិកាព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា តំណាងក្រសួងផែនការ ក្រសួងមហាផ្ទៃ និងសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន សរុបចំនួន៣២៣នាក់។

ថ្លែងក្នុងឱកាសបើកអង្គវេទិកា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានវាយតម្លៃខ្ពស់ចំពោះក្រុមសមាជិកាព្រឹទ្ធសភា ដែលបានផ្ដួចផ្ដើមគំនិត និងមានកិច្ចសហការល្អជាមួយនឹងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរខេត្ត ក្នុងការរៀបចំវេទិកាក្នុងគោលបំណងប្រមូលផ្ដុំគំនិត ចែករំលែកចំណេះដឹង បទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក សំដៅរួមគ្នាលើកកម្ពស់បន្ថែមនូវសមត្ថភាពដឹកនាំ ការយល់ដឹងក្នុងវិស័យច្បាប់ និងការដោះស្រាយវិវាទក្រៅប្រព័ន្ធ ដល់សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទី ភារកិច្ចរបស់ខ្លួនក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមូលដ្ឋាន



*ទិដ្ឋភាពអ្នកចូលរួមវេទិកា*

ឱ្យកាន់តែល្អប្រសើរ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានបញ្ជាក់ថា វេទិកានាពេលនេះ ពិតជាមានគោលដៅលើកកម្ពស់ក្នុងការកសាងសមត្ថភាពដឹកនាំ ដែលជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់សម្រាប់យកទៅធ្វើការផ្សព្វផ្សាយ អនុវត្ត និងវាយតម្លៃ ដើម្បីធ្វើឱ្យសម្រេចបានក្នុងការអភិវឌ្ឍមូលដ្ឋាន និងជួយពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងការការពារផ្លូវច្បាប់សម្រាប់ស្ត្រីក្មេងស្រី ស្ត្រីពិការ ជនងាយរងគ្រោះ ព្រមទាំងជួយលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

តាមរយៈវេទិកានោះ ឯកឧត្តមសង្ឃឹមថា អ្នកចូលរួមទាំងអស់ ជាពិសេសសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នឹងទទួលបានចំណេះដឹង ចំណេះធ្វើ បទពិសោធន៍ ដំណោះស្រាយថ្មីៗ ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនក្នុងការផ្តល់សេវាកន្លងមក។ ឯកឧត្តមបានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ ពិសេសសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ជួយផ្តល់គំនិតយោបល់ ក្នុងន័យចែករំលែកព័ត៌មាន ចំណេះដឹង បទពិសោធន៍ល្អៗ និងបញ្ហាប្រឈមនានា ដែលជាឧបសគ្គដល់ស្ត្រី និងតម្រូវការជាក់ស្តែងរបស់ស្ត្រី សម្រាប់ជាគុណប្រយោជន៍ស្វែងរកដំណោះស្រាយឱ្យចំបញ្ហានៅសេសសល់ដែលកើតមាន ដើម្បីជំរុញការអភិវឌ្ឍមូលដ្ឋានឱ្យកាន់តែល្អប្រសើរ។

សូមជម្រាបថា អង្គវេទិកាប្រព្រឹត្តទៅរយៈពេលមួយថ្ងៃដោយដំណើរការតាមកម្មវិធី ដូចខាងក្រោម៖

១-មតិស្វាគមន៍របស់ឯកឧត្តម **ទៀ សីហា** អភិបាល នៃគណៈអភិបាលខេត្តសៀមរាប។



*លោកជំទាវ មាន សំអាន ឡើងមានចំណាប់អារម្មណ៍ក្នុងអង្គវេទិកា*

២-ចំណាប់អារម្មណ៍របស់លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភាស្តីពី ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៣-មានការចាក់បញ្ចាំងខ្សែវីដេអូស្តីពី ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងស្តីពីវឌ្ឍនភាពការងាររបស់ក្រុមសមាជិកព្រឹទ្ធសភាឆ្នាំ២០២១។

៤-បទបង្ហាញដោយលោកជំទាវ **ម៉ុំ សណ្ដាប់** អនុប្រធានក្រុមសមាជិកាព្រឹទ្ធសភាស្តីពី តួនាទី ភារកិច្ច មុខងារ រចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា។

៥-បទបង្ហាញដោយឯកឧត្តម **ហ៊ី តាំងអេង** រដ្ឋលេខាធិការក្រសួងផែនការស្តីពី ស្ត្រីក្នុងដំណើរការកសាង និងអនុវត្តកម្មវិធីវិនិយោគអភិវឌ្ឍន៍សាមីមូលដ្ឋាន។

៦-បទបង្ហាញដោយឯកឧត្តម **សូ មុនីរក្សា** នាយកសាលាជាតិរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសេវារដ្ឋបាលក្នុងការអភិឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

៧-បទបង្ហាញដោយលោកស្រី **ខាញ់ សុទី** អនុប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋានស្តីពី តួនាទី ភារកិច្ចរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

៨-បទបង្ហាញដោយឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ស្តីពីការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការផ្សះផ្សាសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។




ទិដ្ឋភាពអ្នកមានមតិយោបល់ក្នុងអង្គវេទិកា

៩-មតិយោបល់អង្គវេទិកា (សំណួរ និងការបកស្រាយរបស់វាគ្មិន)។

១០-មតិបូកសរុប និងបិទអង្គវេទិកា ដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា។

បន្ទាប់ពីអង្គវេទិកាពិភាក្សាគ្នាយ៉ាងផុសផុលអស់រយៈពេល១ថ្ងៃរួចមក លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា បានធ្វើការបូកសរុប និងបិទអង្គវេទិកា ដោយបានវាយតម្លៃខ្ពស់ចំពោះអង្គវេទិកា ដែលបានឆ្លុះបញ្ចាំងពីការផ្តល់សេវារដ្ឋបាល ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការងារសង្គមកិច្ច និងសុវត្ថិភាពសង្គម ស្របតាមប្រធានបទដែលបានកំណត់។ ការទទួលស្គាល់ភាពចាំបាច់នៃការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី ជាមូលដ្ឋានគ្រឹះដ៏មានសារៈសំខាន់ សម្រាប់យកទៅអនុវត្តន៍ការងារឱ្យកាន់តែមានប្រសិទ្ធភាពប្រកបដោយសីលធម៌ គុណធម៌ មនសិការវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព និងស័ក្តិសិទ្ធិភាពជូនប្រជាពលរដ្ឋនៅមូលដ្ឋាន។

លោកជំទាវ **មាន សំអាន** បានសម្តែងនូវសេចក្តីរីករាយ ដែលបានសង្កេតឃើញថា អ្នកចូលរួមក្នុងអង្គវេទិកាមានទស្សនវិស័យដូចគ្នា និងមានជំហររួមគ្នាក្នុងការបន្តលើកកម្ពស់សមភាពយេនឌ័រ ការផ្តល់សិទ្ធិអំណាច និងការគាំទ្រដល់ស្ត្រី ដែលជាគុណតម្លៃសម្រាប់ការលើកកម្ពស់គុណភាពសេវាសាធារណៈ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ ដើម្បីទទួលបានជំនឿជឿជាក់ ការចូលរួម និងការគាំទ្រពីប្រជាពលរដ្ឋ។ អង្គវេទិកានាថ្ងៃនេះ បានរួមចំណែកលើកទឹកចិត្តគាំទ្រជួយពង្រឹងសមត្ថភាពដឹកនាំ ដើម្បីធ្វើជាមូលដ្ឋានក្នុងការជំរុញ និងចូលរួមឱ្យកាន់តែសកម្ម ស័ក្តិសមជាអ្នកតំណាងរបស់ប្រជាពលរដ្ឋដែលបានបោះឆ្នោតគាំទ្រ៕

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ គង់ យ៉ារីន)



លោកជំទាវ មាន សំអាន អញ្ជើញមានមតិបូកសរុបបិទអង្គវេទិកា

# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញសម្ពោធសមិទ្ធផលនានា នៅវត្តតាំងក្រសាំងខាងជើង



ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញសម្ពោធសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង

កុដិ និងសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង ស្ថិតនៅក្នុងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ត្រូវបានប្រារព្ធពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២២។

ពិធីនោះមានការអញ្ជើញចូលរួមពីសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ទីប្រឹក្សា ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សាលារាជធានីភ្នំពេញ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងបងប្អូនពុទ្ធបរិស័ទចំណុះជើងវត្តយ៉ាងច្រើនកុះករ។

ក្នុងឱកាសនោះ ឯកឧត្តម **ភើត ឆៃ** អភិបាលរងរាជធានីភ្នំពេញ បានជម្រាបជូនអង្គពិធីជ្រាបអំពីសមិទ្ធផល ដែលត្រូវសម្ពោធដាក់ឱ្យដំណើរការប្រើប្រាស់ជាផ្លូវការ នាពេលនោះរួមមាន៖ កសាងពុទ្ធបដិមាករព្រះពុទ្ធប្រោសបញ្ចវគ្គីយ៍ ដំបូលព្រះវិហារ កសាងកុដិថ្មីមួយខ្នង ភ្ជាប់ជាមួយនឹងការជាវព្រះអង្គព្រះពុទ្ធថ្មកែវចំនួន២៦អង្គ ដាក់តម្កល់ក្នុងកុដិនេះទុកជាទីសក្ការបូជា និងសាងសង់របងវត្តជាថ្មី ចាក់សាប ក្រាលការ៉ូឡាក្នុងទីធ្លាវត្ត សួនច្បារ និងធ្វើប្រព័ន្ធផ្លូវបេតុង សាងសង់ផ្លូវបេតុងចូលវត្ត ផ្លូវបេតុងខាងក្រៅវត្ត និងខ្លោងទ្វារចូលវត្ត ព្រមទាំងក្រាលក្រួសក្រហមពីខាងត្បូងវត្ត ទុកប្រើប្រាស់ជាផ្លូវសាធារណៈ។

ក្នុងឱកាសដ៏មហោឡារិកនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានសម្តែងនូវការសប្បាយរីករាយជាអតិបរមាពោរពេញទៅដោយកិត្តិយស និងមោទនភាពយ៉ាងក្រៃលែង ដែលបានចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង ហើយក៏ជាការបញ្ជាក់ឱ្យឃើញអំពីការរីកចម្រើនខាងវិស័យព្រះពុទ្ធសាសនា ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ព្រះគ្រូចៅអធិការវត្ត គណៈកម្មការអាចារ្យវត្ត ពុទ្ធបរិស័ទចំណុះជើងវត្ត ព្រមទាំងការជួយឧបត្ថម្ភរបស់ពុទ្ធសាសនិកជិតឆ្ងាយ នៃវត្តតាំងក្រសាំងខាងជើង។

ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានរំលឹកអំពីការកកើតវត្តតាំងក្រសាំងខាងជើង ក្នុងឆ្នាំ១៤២៤ នៃសម័យលង្វែក និងការបំផ្លិចបំផ្លាញក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ព្រមទាំងការរស់ឡើងវិញក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ វត្តតាំងក្រសាំងខាងជើងនេះ នៅសល់តែព្រះវិហារដែលគ្មានដំបូល និងពុទ្ធបដិមាមួយអង្គតែប៉ុណ្ណោះ។ លុះដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៨៩ វត្តនេះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឡើងវិញ តាមគោលនយោបាយរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ បច្ចុប្បន្ន កម្ពុជាមានវត្តអារាមចំនួន៥.១០៤វត្ត និងព្រះសង្ឃចំនួន៧០.៩០៥អង្គ ក្នុងនោះគណៈមហានិកាយចំនួន៤.៨៤៣វត្ត និងគណៈធម្មយុត្តិកនិកាយចំនួន២៦១វត្ត។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាកំពុងតែឈរស្មើមុខស្មើមាត់នឹងប្រទេសដទៃទាំងអស់នៅលើពិភពលោក។ ក្នុងឆ្នាំ២០២១ កន្លងទៅ កម្ពុជាបានទទួលធ្វើជាប្រធានដឹកនាំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធវីដេអូ ដែលមាន



ទិដ្ឋភាពក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង

ការចូលរួមពីបណ្តាថ្នាក់ដឹកនាំនៃប្រទេសនៅអឺរ៉ុប និងអាស៊ីជាង៥៨ប្រទេស។ រីឯក្នុងខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅថ្មីៗនេះ ក៏បានធ្វើជាប្រធានប្តូរវេននៃកិច្ចប្រជុំកំពូលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថាអាស៊ាន) លើកទី៤០ និង៤១ និងជាប្រធានប្តូរវេន នៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ហៅកាត់ថា AIPA) ផងដែរ។ ការធ្វើជាម្ចាស់ផ្ទះ និងដឹកនាំកិច្ចប្រជុំកំពូលកម្រិតតំបន់ និងពិភពលោកនេះ បានសបញ្ជាក់ឱ្យឃើញថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលពោរពេញទៅដោយសុខសន្តិភាពពេញបរិបូរណ៍ មានសុវត្ថិភាពគ្រប់ទីកន្លែង និងមានការអភិវឌ្ឍ ក្រោមចក្ខុវិស័យវែងឆ្ងាយ និងភាពប៉ិនប្រសព្វផ្នែកនយោបាយការទូតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះ ប្រទេសកម្ពុជាបានឆ្លងផុតដំណាក់កាលដ៏គ្រោះថ្នាក់ពីការវាយលុកជំងឺកូវីដ-១៩ដ៏កាចសាហាវ និងកំពុងតែងើបឡើងវិញពីផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម ហើយអាចយកឈ្នះទៅលើជំងឺនេះ និងបានបើកប្រទេសឡើងវិញទាំងស្រុងតាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១មក គឺអាស្រ័យដោយកត្តាធំៗចំនួន៣៖ ទី**១**- រាជរដ្ឋាភិបាលគ្រប់គ្រងស្ថានការណ៍បានល្អ និងមានការដាក់ចេញផែនការ និងយុទ្ធសាស្ត្របានត្រឹមត្រូវសមស្របតាមសភាពការណ៍ជាក់ស្តែង ទី**២**-ដោយសារតែប្រជាជនកម្ពុជា ជាច្រើនលើសលប់ចូលរួមជាមួយនឹងរាជរដ្ឋាភិបាល គឺជាង៩៥,១៦% នៃ១៦លាននាក់ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងមួយចំនួនធំបានចាក់ដូសជំរុញទី៤ និងទី៥ និងមានថ្នាំព្យាបាលគ្រប់គ្រាន់លើទីផ្សារក្នុងតម្លៃសមរម្យបំផុត និងទី**៣**-ប្រជាពលរដ្ឋចូលរួមអនុវត្តវិធានការការពារ គឺ៣កុំ ៣ការពារដោយម៉ត់ចត់។ ជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តវិធានការកែទម្រង់ ព្រមទាំងវិធានការគាំទ្រចាំបាច់នានាសំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការលើកកម្ពស់ និងជំរុញវិស័យឯកជន ទាំងក្នុងសកម្មភាពធុរកិច្ច ពាណិជ្ជកម្ម និងវិនិយោគ ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗដែលកើតចេញពីការប្រែប្រួលនិន្នាការនានាក្នុងពិភពលោក ជាពិសេសការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មខ្សែច្រវាក់ផលិតកម្ម និងការកើនឡើង នៃការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនថ្មីៗ និងបច្ចេកវិទ្យាឌីជីថល ទាំងក្នុងក្របខ័ណ្ឌប្រទេស តំបន់ និងសកលពោលគឺ ការដាក់ឱ្យអនុវត្ត "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចក្នុងការរស់នៅជាមួយនឹងកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣" ដែលនេះ គឺជាការដើរទាន់ ឬមុនសភាពការណ៍ក្នុងគោលបំណងបង្ការ និងលើកស្ទួយជីវភាពប្រជាជនទូទៅ។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេព ខន** បានអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការបម្រើប្រជាពលរដ្ឋដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីដោះស្រាយកង្វល់ និងទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបន្តអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ឱ្យបានជាប់ជាប្រចាំនៅគ្រប់មូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា នៅតាមមូលដ្ឋានរបស់ខ្លួន ដូចជាសកម្មភាពលួច ឆក់ ប្លន់ បទល្មើសគ្រឿងញៀនខុសច្បាប់ ល្បែងស៊ីសងខុសច្បាប់ ការជួញដូរមនុស្ស និងសកម្មភាពក្មេងទំនើងជាដើម។ ហើយបងប្អូនប្រជាពលរដ្ឋត្រូវខិតខំអប់រំកូនក្មួយទាំងអស់កុំឱ្យប្រើប្រាស់គ្រឿងញៀន ត្រូវចៀសឆ្ងាយពីគ្រឿងញៀន ដែលនាំឱ្យមានការបំផ្លាញខ្លួនឯង និងនាំមកនូវភាពមហន្តរាយដល់សង្គមជាតិ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)





*ទិដ្ឋភាពក្នុងពិធីសម្ភោធសមិទ្ធផលនានា ក្នុងវត្តតាំងក្រសាំងខាងជើង*

# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភាអញ្ជើញសម្ពោធសមិទ្ធផលនានា និងស្រោចស្រពសុគន្ធវារីប្រគេនព្រះចៅអធិការវត្តព្រែកជ្រៃ




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញសម្ពោធសមិទ្ធផលនានា ក្នុងវត្តព្រែកជ្រៃ*

នាព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសម្ពោធឧបដ្ឋានសាលា ខ្លោងទ្វារ សមិទ្ធផលនានា និងពិធីស្រោចស្រពសុគន្ធវារីប្រគេនព្រះចៅអធិការវត្តព្រែកជ្រៃ(ហៅវត្តជ្រោយបទុម) ស្ថិតក្នុងភូមិបាគូ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះឯកឧត្តម **ម៉ប់ សារិន** ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ បានជម្រាបជូនអង្គពិធីជ្រាបអំពីសមិទ្ធផលដែលត្រូវសម្ពោធដាក់ឱ្យដំណើរការប្រើប្រាស់ជាផ្លូវការរួមមាន៖ សាលាឆាន់ កុដិ ខ្លោងទ្វារ រោងភត្ត ផ្ទាំងសិលាចារឹក សាវតារវត្ត ជួសជុលព្រះវិហារ និងការដាំដើមឈើ ២.១៥០ដើម និងចាក់ដីបំពេញទីធ្លាវត្ត ព្រមទាំងរៀបចំបង្គោលភ្លើងសូឡាបំភ្លឺក្នុងវត្តចំនួន៥២បង្គោល សមិទ្ធផលទាំងអស់សរុបថវិកាចំនួន៨១១.៦៧៥ដុល្លារអាមេរិក។




*ឯកឧត្តម ម៉ប់ សារិន ឡើងអានរបាយការណ៍អំពីសមិទ្ធផលនានា*

ក្នុងពិធីដ៏អធិកអធមនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានរំលឹកអំពីការកសាងវត្តព្រែកជ្រៃដែលមានអាយុកាលប្រហែល១៤១ឆ្នាំ និងជាកន្លែងសិក្សារៀនសូត្រ បណ្តុះបណ្តាលពហុជំនាញ ចំណេះដឹងផ្សេងៗ ជាពិសេសជាមជ្ឈមណ្ឌលអប់រំសីលធម៌ សុជីវធម៌ ដែលជាអត្តសញ្ញាណជាតិ និងជាកន្លែងបំពេញបុណ្យកុសល ទានសីល ភាវនាជាដើម។ ក្រោយឆ្នាំ១៩៧០ ដោយប្រទេសជាតិមានភាពវឹកវរខាងនយោបាយ ជម្លោះផ្ទៃក្នុង ធ្លាក់ក្នុងរបបប្រល័យពូជសាសន៍ដ៏ខ្មៅងងឹត និងកើតសង្គ្រាមពាសពេញផ្ទៃប្រទេស ដែលជាហេតុនាំឱ្យវត្តនេះពុំបានកសាងសំណង់វត្តសោះឡើយ និងបានរងការ

បំផ្លិចបំផ្លាញពីពួកប៉ុលពតទៅទៀត។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ទីវត្តទាំងមូលនៅសល់តែដីទទេ គ្មានសេសសល់សំណង់អ្វីបន្តិចបន្តួច ដែលជាហេដ្ឋារចនាសម្ព័ន្ធរបស់វត្តឡើយ។ លុះដល់ឆ្នាំ១៩៨២ ទើបទីអារាមមួយនេះត្រូវបានកសាងឡើងវិញ។



ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញសំណេះសំណាលជាមួយប្រជាពលរដ្ឋ

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានថ្លែងនូវការកោតសរសើរចំពោះមូលដ្ឋានខណ្ឌដង្កោ ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងផ្នែកអាណាចក្រ និងផ្នែកពុទ្ធចក្រ។ ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាកំពុងតែឈរស្មើមុខស្មើមាត់ជាមួយនឹងប្រទេសដទៃទាំងអស់នៅលើពិភពលោក ដោយក្នុងនោះប្រទេសកម្ពុជាបានទទួលធ្វើជាប្រធានដឹកនាំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធវីដេអូ កាលពីឆ្នាំ២០២១ ហើយកាលពីខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅថ្មីៗ ព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើជាប្រធានដឹកនាំប្តូរវេនកិច្ចប្រជុំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ហៅកាត់ថាអាស៊ាន) លើកទី៤០ និង៤១ និងជាប្រធានប្តូរវេនដឹកនាំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ (ហៅកាត់ថា AIPA) ផងដែរ។ អ្វីៗទាំងអស់នេះបានសបញ្ជាក់ឱ្យឃើញថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលពោរពេញទៅដោយសុខសន្តិភាពពេញបរិបូរណ៍ មានសុវត្ថិភាពគ្រប់ទីកន្លែង និងការអភិវឌ្ឍ ក្រោមចក្ខុវិស័យដ៏វែងឆ្ងាយ និងភាពប៉ិនប្រសព្វផ្នែកនយោបាយការទូតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ ប្រទេសកម្ពុជាក៏បានឆ្លងផុតដំណាក់កាលដ៏គ្រោះថ្នាក់ពីការវាយលុកជំងឺកាចសាហាវកូវីដ-១៩ និងកំពុងតែងើបឡើងវិញពីផលប៉ះពាល់សេដ្ឋកិច្ច និងសង្គម និងបានបើកប្រទេសឡើងវិញទាំងស្រុងតាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។



ទិដ្ឋភាពអ្នកចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តព្រែកជ្រៃ

ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តវិធានការកែទម្រង់ ព្រមទាំងវិធានការគាំទ្រចាំបាច់នានា សំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការលើកកម្ពស់ និងជំរុញវិស័យឯកជន ទាំងក្នុងសកម្មភាពធុរកិច្ច ពាណិជ្ជកម្ម និងវិនិយោគ ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗដែលកើតចេញពីការប្រែប្រួលនិន្នាការនានាក្នុងពិភពលោក ជាពិសេសការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មខ្សែច្រវាក់ផលិតកម្ម និងការកើនឡើង នៃការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនថ្មីៗ និងបច្ចេកវិទ្យាឌីជីថល ទាំងក្នុងក្របខ័ណ្ឌប្រទេស តំបន់ និងសកល។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងកងកម្លាំងមានសមត្ថកិច្ចដែលបានប្តេជ្ញាចិត្តរួមគ្នាក្នុងការបំពេញតួនាទី ភារកិច្ចប្រកបដោយការទទួលខុសត្រូវ សម្រេចបានសមិទ្ធផលលើគ្រប់វិស័យ ថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានអំពាវនាវដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការបម្រើប្រជាពលរដ្ឋដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីដោះស្រាយកង្វល់ និងទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបន្តអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាពឱ្យបានជាប់ជាប្រចាំនៅគ្រប់មូលដ្ឋាន ដើម្បីបង្ការ ទប់ស្កាត់ និងបង្រ្កាបបទល្មើសនានានៅតាមមូលដ្ឋានរបស់ខ្លួនដូចជា៖ សកម្មភាពលួច ឆក់ ប្លន់ បទល្មើសគ្រឿងញៀនខុសច្បាប់ ល្បែងស៊ីសងខុសច្បាប់ ការជួញដូរមនុស្ស និងសកម្មភាពក្មេងទំនើងជាដើម៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ស្រោចស្រពសុគន្ធវារី ប្រគេនព្រះចៅអធិការវត្តព្រែកជ្រៃ*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញបំពាក់គ្រឿងឥស្សរិយយស ប្រគេនព្រះចៅអធិការវត្តព្រែកជ្រៃ*



*ឧបដ្ឋានសាលាវត្តព្រែកជ្រៃ (ហៅវត្តជ្រោយបទុម)*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសហការរៀបចំសិក្ខាសាលាស្តីពី "កម្ពុជា-ចិនរួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩"



*ឯកឧត្តម វ៉ាង វិនធាន និងឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

នារសៀលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា មានរៀបចំសិក្ខាសាលាស្តីពី "កម្ពុជា-ចិនរួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩" ក្រោមអធិបតីភាពបើករបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងឯកឧត្តម **វ៉ាង វិនធាន** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

សិក្ខាសាលានោះរៀបចំដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រោមកិច្ចសហការជាមួយនឹងវិទ្យុមិត្តភាពកម្ពុជា-ចិន នៃអគ្គវិទ្យុ និងទូរទស្សន៍មជ្ឈិមចិន និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន ដោយមានការអញ្ជើញចូលរួមពីព្រឹទ្ធសភា ក្រសួងសុខាភិបាល ក្រុមគ្រូពេទ្យជំនាញវេជ្ជសាស្ត្រយោធាចិនជួយកម្ពុជា ក្រុមអ្នកជំនាញវេជ្ជសាស្ត្របុរាណចិនជួយកម្ពុជាទប់ស្កាត់កូវីដ-១៩ អ្នកជំនាញវេជ្ជសាស្ត្រកម្ពុជា ក្រុមគ្រូពេទ្យកម្ពុជាជាង១០០នាក់។



*ឯកឧត្តម អ៊ុំ សារឹទ្ធ ឡើងថ្លែងសុន្ទរកថាក្នុងអង្គសិក្ខាសាលា*

បន្ទាប់ពីការឡើងថ្លែងសុន្ទរកថារបស់ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា លោក **ឈួយ ឈុនឡាយ** ប្រធានការិយាល័យមូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍប្រចាំនៅកម្ពុជា និងលោកជំទាវ **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាលរួចមក ឯកឧត្តម **វ៉ាង វិនធាន** ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា ការកែសម្រួលគោលនយោបាយបង្ការ និង





*ទិដ្ឋភាពអ្នកចូលរួមក្នុងអង្គសិក្ខាសាលា*



*លោក ឈួយ ឈុនឡាយ ប្រធានការិយាល័យមូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍប្រចាំនៅកម្ពុជា*



*លោកជំទាវ យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាល*

គ្រប់គ្រងជំងឺរាតត្បាតរបស់ប្រទេសចិន ឆ្លុះបញ្ចាំងពីជំហររបស់ប្រជាជន និងស្មារតី នៃការស្វែងរកការពិត និងជឿនលឿនទៅតាមសម័យកាល។ រដ្ឋាភិបាលចិនបានបង្កើនប្រសិទ្ធភាព និងកែសម្រួលវិធានការបង្ការ និងគ្រប់គ្រងជំងឺរាតត្បាតទៅតាមពេលវេលា និងស្ថានភាព។ គោលបំណងគឺដើម្បីកាត់បន្ថយផលប៉ះពាល់ នៃការរាតត្បាតរបស់មេរោគមកលើជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ការពារឱ្យមានប្រសិទ្ធភាព និងប្រកបដោយវិទ្យាសាស្ត្រ នូវសុវត្ថិភាពអាយុជីវិតប្រជាជន និងធានាឱ្យបាននូវដំណើរការប្រកបដោយសណ្ដាប់ធ្នាប់ នៃសេដ្ឋកិច្ច និងសង្គម។ ស្របពេលជាមួយគ្នានេះ ការកែសម្រួលគោលនយោបាយបង្ការ និងគ្រប់គ្រងជំងឺរាតត្បាតរបស់ប្រទេសចិន គឺអំណោយផលដល់ការផ្លាស់ប្ដូរស៊ីជម្រៅជាមួយនឹងពិភពខាងក្រៅ និងការចាក់បញ្ចូលថាមពលវិជ្ជមានចូលទៅក្នុងការងើបឡើងវិញ នៃសេដ្ឋកិច្ចពិភពលោក។

មានប្រសាសន៍ក្នុងឱកាសបើកអង្គសិក្ខាសាលានាពេលនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភាបានបញ្ជាក់ថា ប្រទេសទាំងពីរ (កម្ពុជា-ចិន) បានជួយគ្នាទៅវិញទៅមក ហើយប្រទេសចិនបានចាត់បញ្ជូនក្រុមគ្រូពេទ្យប្រយុទ្ធប្រឆាំងជំងឺឆ្លងជាច្រើនលើក ព្រមទាំងបរិច្ចាគសម្ភារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក៏ដូចជាវ៉ាក់សាំងការពារជំងឺកូវីដ-១៩ជាច្រើនដូស និងច្រើនលើកមកកាន់ប្រទេសកម្ពុជា ជួយឱ្យកម្ពុជាទទួលបានលទ្ធផលល្អក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩។ រដ្ឋាភិបាលក៏ដូចជាប្រជាជននៃប្រទេសទាំងពីរកម្ពុជា-ចិន នៅ



*ឯកឧត្តម វ៉ាង វិនធាន ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា ឡើងមានប្រសាសន៍ក្នុងឱកាសបើកអង្គសិក្ខាសាលា*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន មានប្រសាសន៍ក្នុងឱកាសបើកអង្គសិក្ខាសាលា*

តែបន្តការជួយយកអាសាគ្នាទៅវិញទៅមក រួមសុខរួមទុក្ខជាមួយគ្នា ជំរុញ និងចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងជំងឺមួយនេះ។ ថ្មីៗនេះ ប្រទេសចិនបានកែសម្រួលវិធានការបង្ការ និងគ្រប់គ្រងជំងឺរាតត្បាតម្តងទៀតដែលនេះគឺជាការសម្របខ្លួនតាមស្ថានភាពជាក់ស្តែង និងជាសកម្មភាពរបស់ប្រទេសចិនខ្លួនឯងផ្ទាល់ដើម្បីបង្កើនភាពត្រឹមត្រូវ នៃការបង្ការ និងគ្រប់គ្រងជំងឺរាតត្បាត ដើម្បីអនុវត្តវិធានការមានប្រសិទ្ធភាពក្នុងការសម្របសម្រួលសុវត្ថិភាព សុខភាព និងការស្តារឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាជនជាប្រក្រតី។

អ្នកចូលរួមក្នុងសិក្ខាសាលាទាំងអស់បានយល់ឃើញជារួមថា កម្ពុជាចិនចាប់ដៃគ្នាឆ្ពោះទៅមុខ តស៊ូជម្នះការលំបាក ដែលនេះបានបង្កើតជាគំរូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩សម្រាប់សហគមន៍អន្តរជាតិ និងបានបង្ហាញថា កម្ពុជា និងចិនគឺជាមិត្តដែកថែបពិតប្រាកដ។ ឈរនៅលើចំណុចចាប់ផ្តើម នៃដំណើរថ្មីប្រទេសកម្ពុជា និងចិននឹងពួតដៃប្រកៀកស្មាគ្នាឆ្ពោះទៅមុខធ្វើឱ្យស៊ីជម្រៅគ្រប់ជ្រុងជ្រោយបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនមានជាអាទិ៍៖ សេដ្ឋកិច្ច ការកសាងហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស វេជ្ជសាស្ត្រជាដើម ដើម្បីគូសវាសគម្រោងថ្មីសម្រាប់ “សហគមន៍ជោគវាសនារួមកម្ពុជាចិន”។



ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ទទួលជំនួយពីឯកឧត្តម វ៉ាង វិនធាន



ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ទទួលវត្ថុអនុស្សាវរីយ៍ពីឯកឧត្តម វ៉ាង វិនធាន

នៅក្នុងសិក្ខាសាលានោះ មូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ ក៏បានផ្តល់អំណោយឧបករណ៍តេស្តរហ័សពិនិត្យរកជំងឺកូវីដ-១៩ ចំនួន៧០ម៉ឺនតេស្ត ជូនដល់ព្រឹទ្ធសភាកម្ពុជាផងដែរ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយ ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា និងភាគីចិន

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង១៥:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា គោរពវិញ្ញាណក្ខន្ធឯកឧត្ដម **ជាំង ជឺមិន** អតីតប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន នៅស្ថានឯកអគ្គរដ្ឋទូតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។




❈នាព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៅគេហដ្ឋានស្ថិតក្នុងសង្កាត់ទន្លេ-បាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។




❈នារសៀលថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយឯកឧត្ដមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព មហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **អ៊ំ សុខ** ញោមបង្កើតរបស់សម្ដេចព្រះពោធិវង្ស **អ៊ំ លឹមហេង** នៅសាលាបុណ្យ ស្ថិតនៅភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្ដាល។




# គណៈកម្មការទី១ព្រឹទ្ធសភា ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ជួបពិភាក្សាលើសំណើរបស់ជនជាតិដើមភាគតិច



*គណៈកម្មការទី១ព្រឹទ្ធសភាជួបពិភាក្សាជាមួយក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ*

នាព្រឹកថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយនឹងក្រសួងបរិស្ថាន ដឹកនាំដោយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងពិភាក្សាលើសំណើរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការកែសម្រួលសេចក្ដីព្រាងច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ និងសេចក្ដីព្រាងច្បាប់ស្ដីពីព្រៃឈើ។

កិច្ចប្រជុំនោះ មានការអញ្ជើញចូលរួមពីគណៈកម្មការទី៣ព្រឹទ្ធសភា រដ្ឋសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ តំណាងក្រសួងការពារជាតិ តំណាងលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៃក្រសួងមហាផ្ទៃ និងរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ក្នុងឱកាសនោះ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានបញ្ជាក់អង្គប្រជុំថា កាលពីពេលថ្មីៗនេះ គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានជួបពិភាក្សាជាមួយនឹងក្រសួងពាក់ព័ន្ធ និងបានជួបជាមួយនឹងតំណាងសហគមន៍ជនជាតិដើមភាគតិច១៦អំបូរជនជាតិ។ នៅក្នុងជំនួបនោះ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលព័ត៌មានយ៉ាងល្អិតល្អន់ពីការបញ្ចូលធាតុចូល ដែលស្នើឡើងដោយតំណាងជនជាតិដើមភាគតិចទៅក្នុងសេចក្ដីព្រាងច្បាប់ថ្មីទាំងពីរ។ ប៉ុន្តែពួកគេនៅតែមានសំណូមពរសុំឱ្យបញ្ចូលចំណុចសេសសល់ និងសុំបន្ថែមចំណុចមួយចំនួនទៀត ដូចជា៖ទី១-គួរមាន



*ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធជួបពិភាក្សាជាមួយគណៈកម្មការទី១ព្រឹទ្ធសភា*



*ក្រសួងពាក់ព័ន្ធ ចូលរួមក្នុងជំនួបពិភាក្សាការងារ*

មាត្រាជាក់លាក់មួយផ្ដល់នីតិសម្បទាដល់សហគមន៍ជន-ជាតិដើមភាគតិច ដែលបានចុះបញ្ជីស្របច្បាប់ជានគរបាលយុត្តិធម៌ ទី**២**-គួរទទួលស្គាល់យន្តការ និងវិធានការប្រពៃណីរបស់ជនជាតិដើមភាគតិចជាមុន មុនទៅដល់យន្តការ និងអនុវត្តទោសតាមច្បាប់រដ្ឋ ក្នុងការដោះស្រាយ និងដាក់ទោសទណ្ឌ និងទី**៣**-សេចក្ដីព្រាងច្បាប់ថ្មី គួរពិចារណា និងផ្អែកទៅលើសេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច និងអនុសញ្ញាលេខ១១១ ស្ដីពីការរើសអើងក្នុងការងារ និងមុខរបរ។

ក្នុងឱកាសនោះដែរ ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានជម្រាបជូនអង្គប្រជុំជ្រាបអំពី សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ជនជាតិដើមភាគតិច បណ្ដាញសហគមន៍ និងលិខិតបទដ្ឋានគតិយុត្ត។ តួនាទីគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ (សហគមន៍ជនជាតិដើមភាគតិច) និងគណៈកម្មការបណ្ដាញសហ-គមន៍។ ការគាំទ្រ និងលទ្ធផលសំខាន់ៗសម្រេចបាន ព្រម-ទាំងបញ្ហាប្រឈមនឹងការគ្រប់គ្រងសហគមន៍ជនជាតិដើមភាគតិច។

បន្ទាប់ពីបានពិភាក្សាគ្នា និងឡើងមានមតិយោបល់របស់ក្រសួងពាក់ព័ន្ធរួចមក ឯកឧត្តម **យ៉ង់ សែម** បានវាយតម្លៃខ្ពស់ និងកោតសរសើរដល់ក្រសួងបរិស្ថាន ដែលមានសុឆន្ទៈដោយខ្លួនឯងមកធ្វើបទបង្ហាញ ព្រមទាំងតំណាងមកពីក្រសួងមហាផ្ទៃ (គ.ជ.អ.ប) ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ក្រសួងការពារជាតិ និងសហការីទាំងអស់ បានយកចិត្តទុកដាក់ខិតខំប្រឹងប្រែងដោះស្រាយសំណើទាំងអស់របស់ជនជាតិដើមភាគតិច ដើម្បីឱ្យបានរស់នៅដោយសុខដុមរមនា ជួយថែរក្សាបរិស្ថានឱ្យបានល្អប្រសើរយូរអង្វែងទុកដល់អ្នកជំនាន់ក្រោយតរៀងទៅ៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



*សមាជិក សមាជិកាព្រឹទ្ធសភា ចូលរួមក្នុងជំនួបពិភាក្សាការងារ*

# គណៈកម្មការទី៥ព្រឹទ្ធសភាចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង




*គណៈកម្មការទី៥ព្រឹទ្ធសភា ចែកអំណោយជូនប្រជាពលរដ្ឋ នៅភូមិឡៅកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី*

ក្នុងអំឡុងពេល នៃចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មការនានារបស់ព្រឹទ្ធសភាត្រូវចុះឈ្វេងយល់វិស័យជាសមត្ថកិច្ចរបស់ខ្លួននៅតាមក្រសួង ស្ថាប័ន និងបណ្តារាជធានី ខេត្តទូទាំងប្រទេស។ ជាក់ស្តែង គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់វិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៥ព្រឹទ្ធសភា នៅខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ពីថ្ងៃទី២២ ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។

គោលបំណង នៃដំណើរបេសកកម្ម គឺដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅលើវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការដូចជា៖ ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេស ការផ្តល់ប័ណ្ណការងារ ការត្រួតពិនិត្យប័ណ្ណ ឬសៀវភៅការងាររបស់ជនបរទេសដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន ការអនុវត្តច្បាប់ស្តីពី របបសារព័ត៌មាន ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ខេត្តដូចជា៖ វិទ្យុ ទូរទស្សន៍ កាសែត ព័ត៌មានអនឡាញ (TV, Facebook) និងទស្សនាវដ្តី ព្រមទាំងប្រមូលព័ត៌មានអំពីប្រសិទ្ធភាព នៃការអនុវត្តការងារ លទ្ធផលការងារ ការអភិវឌ្ឍលើវិស័យនានា បញ្ហាប្រឈម និងសំណូមពរនានារបស់ខេត្ត។

ក្នុងដំណើរបំពេញបេសកកម្មនារសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយទៅចែកជូនដល់បងប្អូនប្រជាពលរដ្ឋក្រីក្រជនជាតិដើមភាគតិចព្នងចំនួន២៣គ្រួសារ នៅភូមិឡៅកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

ដោយឡែកនាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធជុំវិញខេត្តមណ្ឌលគិរី ដឹកនាំដោយឯកឧត្តម **ថង សាវុន** អភិបាល




*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តមណ្ឌលគិរី*



*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុកកែវសីមា និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនទ្វេភាគីឡាប៉ាខេ*



*គណៈកម្មការទី៥ព្រឹទ្ធសភាថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនទ្វេភាគីឡាប៉ាខេ*

នៃគណៈអភិបាលខេត្ត និងឯកឧត្តម **ម៉ែន ខ៉ុយ** ប្រធានក្រុមប្រឹក្សាខេត្តមណ្ឌលគិរី នៅសាលាខេត្តមណ្ឌលគិរី។

បន្ទាប់មកនៅរសៀលថ្ងៃដដែល គណៈប្រិតភូបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរស្រុកកែវសីមា និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនទ្វេភាគីឡាប៉ាខេ ដឹកនាំដោយលោក **យិន សុខឡេង** អភិបាលរងស្រុកកែវសីមា អាជ្ញាធរស្រុកពេជ្រាដា និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនទ្វេភាគីណាមលៀ ដឹកនាំដោយលោក **ខាំផន ជា** អភិបាលរងស្រុកពេជ្រាដា និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរស្រុកដាក់ដាំ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនទ្វេភាគីដាក់ដាំ ដឹកនាំដោយលោក **យុខ តារ៉ា** អភិបាលរងស្រុកដាក់ដាំ ដើម្បីឈ្វេងយល់អំពីសកម្មភាពទូទៅរបស់ស្រុក ការគ្រប់គ្រងច្រកទ្វារព្រំដែនទ្វេភាគី ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការគ្រប់គ្រងជនបរទេសឆ្លងដែន ការអភិវឌ្ឍលើវិស័យនានា ព្រមទាំងបានចុះពិនិត្យមើលសកម្មភាពចេញ-ចូលរបស់ភ្ញៀវជាតិអន្តរជាតិ និងការប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋនៅតាមច្រកទ្វារព្រំដែនទ្វេភាគីនីមួយៗ។

បន្ទាប់ពីបញ្ចប់បេសកកម្មនៅខេត្តមណ្ឌលគិរី នាព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានបន្តធ្វើដំណើរទៅកាន់ខេត្តរតនគិរី ដើម្បីជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរស្រុក និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ដឹកនាំដោយលោក **ហេង ប៊ុន្នី** អភិបាលស្រុកអូរយ៉ាដាវ នៅច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ។

បន្ទាប់មកនាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ គណៈ-





*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុក និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ*



*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តរតនគិរី*



*គណៈកម្មការទី៥ព្រឹទ្ធសភាប្រគល់វត្ថុអនុស្សាវរីយ៍ជូនអាជ្ញាធរខេត្តរតនគិរី*

ប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្ត និងមន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តរតនគិរី ដឹកនាំដោយឯកឧត្ដម **ញ៉ែម សំអឿន** អភិបាល នៃគណៈអភិបាលខេត្តរតនគិរី នៅសាលាខេត្តរតនគិរី។

នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា បានបន្តដំណើរទៅកាន់ខេត្តស្ទឹងត្រែង ដើម្បីជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្ត និងមន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តរតនគិរី ដឹកនាំដោយឯកឧត្ដម **ស៊ី សួន** អភិបាលស្ដីទី នៃគណៈអភិបាលខេត្តស្ទឹងត្រែង នៅសាលាខេត្តស្ទឹងត្រែង។



*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង*

បន្ទាប់មកគណៈប្រតិភូបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរស្រុកបុរីអូរស្វាយសែនជ័យ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងគ្រៀល ដឹកនាំដោយលោក **ស្វាយ ពុទ្ធារ៉ា** អភិបាលរងស្រុកស្ទឹងត្រែងបុរីអូរស្វាយសែនជ័យ នៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងគ្រៀល។

តាមរយៈជំនួបពិភាក្សាការងារដាច់ដោយឡែកពីគ្នា ជាមួយនឹងអាជ្ញាធរខេត្តទាំងបី និងនៅតាមច្រកទ្វារអន្តរជាតិនីមួយៗ។ ឯកឧត្ដម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរខេត្ត ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួន ដែលធ្វើឱ្យខេត្តមានការរីកចម្រើន។ ជាមួយគ្នានោះ ឯកឧត្ដមបានសម្ដែងនូវសេចក្ដីរីករាយដែលមើលឃើញខេត្តទាំងបីមានការអភិវឌ្ឍ និងការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលនេះជាសក្ដានុពលដ៏សំខាន់ណាស់សម្រាប់ការទាក់ទាញអ្នកវិនិយោគ មកធ្វើការវិនិយោគនៅក្នុងខេត្ត។

ឯកឧត្ដម **ឈិត គឹមយាត** បានជំរុញឱ្យអាជ្ញាធរខេត្ត ក៏ដូចជាអាជ្ញាធរនៅតាមច្រកទ្វារព្រំដែននីមួយៗ ត្រូវបន្តយកចិត្តទុកដាក់ទប់ស្កាត់អំពើឆ្លងដែនខុសច្បាប់របស់ប្រជាពលរដ្ឋ និងជនបរទេស និងខិតខំពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការនៅតាមច្រកទ្វារព្រំដែននីមួយៗ ជាមួយនឹងប្រទេសជិតខាងឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីបង្កើនលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។ ចំពោះបញ្ហាប្រឈម និងសំណូមពរផ្សេងៗរបស់អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ ដែលបានលើកឡើង គណៈកម្មការទី៥ព្រឹទ្ធសភានឹងពាំនាំ ហើយធ្វើជារបាយការណ៍ជម្រាបជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធដើម្បីធ្វើការដោះស្រាយរួមគ្នា៕

(អត្ថបទ និងរូបភាព៖ នុត សច្ចៈ)





*គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរស្រុកបុរីអូរស្វាយសែនជ័យ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងគ្រៀល*

# គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួននៅខេត្តចំនួន៤






*គណៈកម្មការទី៨ព្រឹទ្ធសភាជួបពិភាក្សាជាមួយអាជ្ញាធរខេត្តបាត់ដំបង*

ក្នុងអំឡុងពេល នៃចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា (គណៈកម្មការទី៨) ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៨ព្រឹទ្ធសភា នៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២។

ក្នុងដំណើរបំពេញបេសកកម្មនោះ នៅរសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធររដ្ឋបាលខេត្តបាត់ដំបង ដឹកនាំដោយឯកឧត្ដម **សឿម ម៉ុនរិទ្ធិ** អភិបាលរង នៃគណៈអភិបាលខេត្ត និងឯកឧត្ដម **អ៊ុយ រី** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តបាត់ដំបង។

បន្ទាប់មកនៅព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធររដ្ឋបាលខេត្តបន្ទាយមានជ័យ ដឹកនាំដោយឯកឧត្ដម **អ៊ុំ រាត្រី** អភិបាល នៃគណៈអភិបាលខេត្ត និងឯកឧត្ដម **ខេង ស៊ុម** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តបន្ទាយមានជ័យ។

ក្នុងឱកាសបំពេញបេសកកម្មនៅខេត្តបន្ទាយមានជ័យ នៅរសៀលថ្ងៃដដែលនោះ គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា អមដំណើរដោយឯកឧត្ដម **ហ៊ិល រ៉ាយ៉ា** អភិបាលរង នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងលោក **គាត ហ៊ុល** អភិបាល នៃគណៈអភិបាលក្រុងប៉ោយប៉ែត បានអញ្ជើញទៅទស្សនកិច្ចឈ្វេងយល់នៅច្រកទ្វារព្រំដែនអន្ដរជាតិប៉ោយប៉ែត និងស្ពានមិត្តភាពកម្ពុជា-ថៃ ច្រកទ្វារព្រំដែនអន្ដរជាតិស្ទឹងបត់ ស្ថិតនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីពិនិត្យមើលពីដំណើរការបច្ចុប្បន្នភាពនៃកំណើនភ្ញៀវទេសចរជាតិ-អន្ដរជាតិ និងកំណើនសេដ្ឋកិច្ចក្នុងបរិបទបើកដំណើរការច្រកទ្វារព្រំដែនឡើងវិញ បន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩។

ដោយឡែកនៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ គណៈ-




*គណៈកម្មការទី៨ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តបន្ទាយមានជ័យ*



គណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចឈ្វេងយល់ នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត និងស្ពានមិត្តភាពកម្ពុជា-ថៃ



គណៈកម្មការទី៨ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តពោធិ៍សាត់

ប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធររដ្ឋបាលខេត្តពោធិ៍សាត់ ដឹកនាំដោយឯកឧត្តម **ខូយ រីដា** អភិបាល នៃគណៈអភិបាលខេត្ត និងឯកឧត្តម **ម៉ក់ រ៉ា** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តពោធិ៍សាត់។

បន្ទាប់ពីបញ្ចប់ជំនួបពិភាក្សាការងារនៅខេត្តពោធិ៍សាត់ នៅព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ រួចមកគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធររដ្ឋបាលខេត្តកំពង់ឆ្នាំង ដឹកនាំដោយឯកឧត្តម **ស៊ុន សុវណ្ណារិទ្ធិ** អភិបាល នៃគណៈអភិបាល



គណៈកម្មការទី៨ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តកំពង់ឆ្នាំង

ខេត្ត លោកជំទាវ **ដោក សុទ្ធា** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលាខេត្តកំពង់ឆ្នាំង។

សូមជម្រាបថា នៅក្នុងជំនួបពិភាក្សាការងារខាងលើ អាជ្ញាធរខេត្តទាំងបួន បានជម្រាបជូនគណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភាជ្រាបអំពីសភាពការណ៍ទូទៅ និងវឌ្ឍនភាពរីកចម្រើនគ្រប់វិស័យ ព្រមទាំងលទ្ធផលការងារដែលសម្រេចបាននាពេលកន្លងទៅ ទិសដៅការងារបន្ត បញ្ហាប្រឈម និងសំណូមពរមួយចំនួន ដែលខេត្តបានជួបប្រទះ។

តាមរយៈជំនួបពិភាក្សាដាច់ដោយឡែកជាមួយនឹងអាជ្ញាធរខេត្តទាំងបួន គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងបំពេញការងារតាមតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋបានយ៉ាងល្អប្រសើរ ទាំងសេវារដ្ឋបាល និងសេវាថែទាំសុខភាព ព្រមទាំងធ្វើឱ្យខេត្តមានការរីកចម្រើនជាបន្តបន្ទាប់លើគ្រប់វិស័យ។ ចំពោះបញ្ហាប្រឈម និងសំណូមពរនានា ដែលអាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធបានលើកឡើង ហើយអាជ្ញាធរខេត្តពុំអាចដោះស្រាយបាន គណៈប្រតិភូគណៈកម្មការទី៨ព្រឹទ្ធសភា នឹងរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរកវិធីដោះស្រាយឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា។

ជាមួយគ្នានោះ គណៈប្រតិភូក៏បានអំពាវនាវឱ្យថ្នាក់ដឹកនាំខេត្ត ក៏ដូចជាមន្ទីរពាក់ព័ន្ធត្រូវប្រុងប្រយ័ត្នជានិច្ចចំពោះជំងឺកូវីដ-១៩ និងស្ដាប់តាមការណែនាំរបស់ក្រសួងសុខាភិបាល ជាពិសេសអាជ្ញាធរ និងប្រជាពលរដ្ឋ នៅតាមព្រំដែន ត្រូវរួមគ្នាទប់ស្កាត់ការចម្លងនៅតាមព្រំដែន កុំឱ្យឆ្លងចូលមកសហគមន៍របស់យើង និងចូលរួមអនុវត្តវិធានការការពារកូវីដ-១៩ គឺ៣ការពារ និង៣កុំ ព្រមទាំងបន្តផ្សព្វផ្សាយដល់បងប្អូនប្រជាពលដែលពុំទាន់បានចាក់វ៉ាក់សាំងឱ្យប្រញាប់ប្រញាល់ទៅចាក់វ៉ាក់សាំងទាំងអ្នកពុំទាន់បានចាក់ និងអ្នកបន្តចាក់ដូសជំរុញផងដែរ។ ក្រៅពីនេះ សូមអាជ្ញាធរខេត្តបន្តចូលរួមទប់ស្កាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន ដើម្បីសុខុមាលភាព ជីវភាព ស្ថិរភាពសណ្ដាប់ធ្នាប់សង្គមជូនដល់បងប្អូនប្រជាពលរដ្ឋឱ្យខានតែបាន៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)

# គណៈកម្មការទី១០ព្រឹទ្ធសភានាំយកអំណោយសម្ដេចប្រធានព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តពោធិ៍សាត់ និងមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ



គណៈកម្មការទី១០ព្រឹទ្ធសភានាំយកឱសថ និងសម្ភារវេជ្ជសាស្ត្រ ប្រគល់ជូនមន្ទីរពេទ្យបង្អែកខេត្តបន្ទាយមានជ័យ

ឱសថ និងសម្ភារវេជ្ជសាស្ត្រ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដីប្រធានព្រឹទ្ធសភា និងលោកជំទាវ ត្រូវបានគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនណាង** ប្រធានគណៈកម្មការ អ្នកនាំពាក្យព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ នាំយកទៅប្រគល់ជូនមន្ទីរពេទ្យបង្អែក និងរដ្ឋបាលខេត្តពោធិ៍សាត់ ព្រមទាំងមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។

ក្នុងដំណើរនាំយកអំណោយរបស់សម្ដេចប្រធានព្រឹទ្ធសភា នៅរសៀលថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា និងមានការអញ្ជើញចូលរួមពីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានអញ្ជើញប្រគល់ឱសថ និងសម្ភារវេជ្ជសាស្ត្រ ជូនមន្ទីរពេទ្យបង្អែក និងរដ្ឋបាលខេត្តពោធិ៍សាត់ ដឹកនាំដោយឯកឧត្តម **ខូយ រីដា** អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ នៅសាលាខេត្តពោធិ៍សាត់។

បន្ទាប់មកនាព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា និងមានការអញ្ជើញចូលរួមពីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានអញ្ជើញនាំយកអំណោយជាឱសថ និងសម្ភារវេជ្ជសាស្ត្រ ប្រគល់ជូនមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តបន្ទាយមានជ័យ ដឹកនាំដោយឯកឧត្តមវេជ្ជបណ្ឌិត **ឡេ ច័ន្ទសង្វាត** ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ នៅមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ។

តាមរយៈពិធីប្រគល់ ទទួលអំណោយដ៏ថ្លៃថ្លារបស់សម្ដេចប្រធានព្រឹទ្ធសភាជូនអាជ្ញាធរខេត្តពោធិ៍សាត់ និងមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ឯកឧត្តម **ម៉ម ប៊ុនណាង**





ទិដ្ឋភាពក្នុងពិធីប្រគល់សម្ភារវេជ្ជសាស្ត្រជូនមន្ទីរពេទ្យបង្អែកខេត្តបន្ទាយមានជ័យ





*គណៈកម្មការទី១០ព្រឹទ្ធសភាបាននាំយកឱសថ និងសម្ភារវេជ្ជសាស្ត្រប្រគល់ជូនមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់*

បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខដោយសេចក្ដីនឹករលឹកយ៉ាងជ្រាលជ្រៅពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះអាជ្ញាធរ និងប្រជាពលរដ្ឋ នៃខេត្តទាំងពីរ។ ឯកឧត្តមបានជម្រាបជូនអង្គពិធីថា អំណោយដ៏ថ្លៃថ្លាទាំងអស់នេះ គឺជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការផ្នែកមនុស្សធម៌រវាងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដែលផ្ដោតសំខាន់លើការលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

ក្នុងឱកាសនោះ អាជ្ញាធរខេត្តទាំងពីរបានសម្ដែងនូវការដឹងគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះព្រឹទ្ធសភា ដែលបាននាំយកឱសថ និងសម្ភារវេជ្ជសាស្ត្រមកប្រគល់ជូនមន្ទីរពេទ្យបង្អែក រដ្ឋបាលខេត្ត និងមន្ទីរសុខាភិបាល។ អាជ្ញាធរខេត្តទាំងពីរបានសន្យាថា នឹងយកអំណោយទាំង-អស់នេះទៅប្រើប្រាស់ឱ្យបានសមស្របតាមគោលបំណងរបស់ព្រឹទ្ធសភា និងអង្គការចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដោយចែកជូនបន្តដល់មន្ទីរពេទ្យបង្អែកខេត្ត មណ្ឌលសុខភាព ក៏ដូចជាអាជ្ញាធរដែនដី និងប្រជាជនងាយរងគ្រោះទូទាំងខេត្ត ដោយឥតគិតថ្លៃ។

សូមជម្រាបថា អំណោយដែលយកទៅប្រគល់ជូនអាជ្ញា-ធរខេត្តទាំងពីរនាពេលនោះ ក្នុងមួយខេត្តទទួលបាន៖ ១-ថ្នាំពេទ្យចំនួន១៤មុខ ស្មើនឹង១៩០កេស ២-សម្លៀកបំពាក់ចំនួន២៩កេស ៣-មួកចំនួន២កេស ៤-ម៉ាស់ចំនួន៨កេស ៥-កាបូបចំនួន២៣០កេស។ ដោយឡែក មន្ទីរពេទ្យបង្អែកស្រុកក្រវាញ ខេត្តពោធិ៍សាត់ ទទួលបានថ្នាំពេទ្យចំនួន៨មុខ ស្មើនឹង៦០កេស៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)



*ទិដ្ឋភាពក្នុងពិធីប្រគល់សម្ភារវេជ្ជសាស្ត្រជូនមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់*



*គណៈកម្មការទី១០ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍*

# ក្រុមមិត្តភាពសភាកម្ពុជា ជាមួយរដ្ឋសភាវៀតណាម អញ្ជើញបំពេញទស្សនកិច្ចការងារ នៅប្រទេសវៀតណាម






*ក្រុមមិត្តភាពសមាជិកសភាកម្ពុជា-វៀតណាម ជួបពិភាក្សាការងារជាមួយនឹងក្រុមហ៊ុនភាគហ៊ុនរួម ជឿង ហាយគ្រុប*

តបតាមការអញ្ជើញរបស់ក្រុមមិត្តភាពសមាជិកសភាវៀតណាម-កម្ពុជា គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-វៀតណាម និងលោកជំទាវ **មាន សំអាន** ប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញបំពេញទស្សនកិច្ចការងារ នៅទីក្រុងដាណាំង និងខេត្តក្វាងណាម ប្រទេសវៀតណាម ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចការងារនៅខេត្តក្វាងណាម ប្រទេសវៀតណាម នាព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមហ៊ុនភាគហ៊ុនរួម ជឿង ហាយគ្រុប ព្រមទាំងឈ្វេងយល់អំពីខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន និងទស្សនារោងចក្រផលិតផលមួយចំនួនរបស់ក្រុមហ៊ុនTHACO និងតំបន់សេដ្ឋកិច្ច CHU LAI នៃកំពង់ផែដឹកជញ្ជូន Tam Hiep តំបន់ទេសចរណ៍ស្ពានមាស និងភូមិបារាំង នៅខេត្តក្វាងណាម ប្រទេសវៀតណាម។

នាល្ងាចថ្ងៃដដែល គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញចូលជួបសម្ដែងការគួរសមឯកឧត្តម **ង្វៀន ឌឹកហាយ** អនុប្រធានរដ្ឋសភាវៀតណាម និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាវៀតណាម-កម្ពុជា នៅសណ្ឋាគារ Nalod ទីក្រុងដាណាំង ខេត្តក្វាងណាម ប្រទេសវៀតណាម។



*លោកជំទាវ មាន សំអាន និងឯកឧត្តម ង្វៀន ឌឹកហាយ*



*ទិដ្ឋភាពក្នុងជួបសម្ដែងការគួរសម*

ក្នុងជំនួបសម្ដែងការគួរសម ភាគីទាំងពីរបានពិភាក្សាគ្នាលើការទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងអង្គការនីតិប្បញ្ញត្តិ និងក្រុមមិត្តភាពសភា នៃប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនខ្លាំងក្លាថែមទៀត។

បន្ទាប់ពីបញ្ចប់ជំនួបសម្ដែងការគួរសម គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ ដែលរៀបចំជូនដោយឯកឧត្តម **ង្វៀន ឌឹកហាយ** អនុប្រធានរដ្ឋសភាវៀតណាម និងជាប្រធានក្រុមមិត្តភាពរដ្ឋសភាវៀតណាម-កម្ពុជា។

បន្ទាប់មកនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញចូលរួមសិក្ខាសាលាផ្លាស់ប្ដូរបទពិសោធន៍ការងាររវាងសភាកម្ពុជា និងរដ្ឋសភាវៀតណាមស្ដីពី ការចែករំលែកតួនាទីសមាជិកសភានៃប្រទេសទាំងពីរ ក្នុងការស្ដារ និងអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចឡើងវិញ ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា ជាមួយនឹងប្រទេសវៀតណាម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ កិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់មេគង្គ សភាអេឡិចត្រូនិក នៅសណ្ឋាគារ Nalod ទីក្រុងដាណាំង ខេត្តក្វាងណាម នៃប្រទេសវៀតណាម។



*ក្រុមមិត្តភាពសមាជិកសភាកម្ពុជាជាមួយរដ្ឋសភាវៀតណាមចូលរួមសិក្ខាសាលាផ្លាស់ប្ដូរបទពិសោធន៍ការងារ*

អង្គសិក្ខាសាលាបានដំណើរការតាមកម្មវិធី ដោយមានការឡើងធ្វើបទអន្តរាគមន៍លើប្រធានបទសំខាន់ៗ ដូចជា៖ បទអន្តរាគមន៍ស្ដីពី តួនាទីរបស់រដ្ឋសភាក្នុងការស្ដារឡើងវិញ នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ បទអន្តរាគមន៍ស្ដីពី កិច្ចសហប្រតិបត្តិការរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រកម្ពុជាលើការអភិវឌ្ឍវិស័យវប្បធម៌ ទេសចរណ៍ និងតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ។ បទអន្តរាគមន៍ស្ដីពី កិច្ចសហប្រតិបត្តិការទន្លេមេគង្គ ការការពារ និងគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ការឆ្លើយតប និងការប្រែប្រួលអាកាសធាតុ។ បទអន្តរាគមន៍ស្ដីពី កិច្ចសហប្រតិបត្តិការទន្លេមេគង្គ ការការពារ និងគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ បទអន្តរាគមន៍ស្ដីពី ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិ និងក្រុមមិត្តភាពសភាវៀតណាម-កម្ពុជា ក្នុងបរិបទបច្ចុប្បន្ន។ បទអន្តរាគមន៍ស្ដីពីទិសដៅ និងយន្តការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ និយាយជារួម និងរវាងក្រុមសមាជិកមិត្តភាពសភា នៃប្រទេសទាំងពីរ និយាយដោយឡែកក្នុងការរួមចំណែកជំរុញកិច្ចសហប្រតិបត្តិការរវាងវៀតណាម-កម្ពុជា កាន់តែស៊ីជម្រៅ ជាក់ស្ដែង និងមានប្រសិទ្ធភាពលើវិស័យ



*ទិដ្ឋភាពក្រុមមិត្តភាពសភាកម្ពុជាជាមួយរដ្ឋសភាវៀតណាម ចូលរួមសិក្ខាសាលា*




*លោកជំទាវ មាន សំអាន ឡើងមានប្រសាសន៍បិទអង្គសិក្ខាសាលា*



*ក្រុមមិត្តភាពសមាជិកសភាកម្ពុជា-វៀតណាម អញ្ជើញចូលជួបសម្ដែងការគួរសម ឯកឧត្តម លឿង ង្វៀន មីញត្រៀត ប្រធានក្រុមប្រឹក្សាភិបាលទីក្រុងដាណាង*

ផ្សេងៗ ក្នុងបរិបទ នៃការអភិវឌ្ឍដ៏ស្មុគស្មាញនៅក្នុងពិភពលោក និងក្នុងតំបន់។ បទអន្តរាគមន៍ស្ដីពី តួនាទីរបស់គណៈកម្មការការពារជាតិ និងសន្តិសុខរបស់រដ្ឋសភា នៃប្រទេសទាំងពីរ ក្នុងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់ នៅតាមតំបន់ជាប់ព្រំដែនវៀតណាម-កម្ពុជា។ បទអន្តរាគមន៍ស្ដីពី កិច្ចសហប្រតិបត្តិការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់នៅតាមតំបន់ព្រំដែន។

មានប្រសាសន៍ក្នុងឱកាសបិទអង្គសិក្ខាសាលា លោកជំទាវ **មាន សំអាន** ប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានចាត់ទុកសិក្ខាសាលានាពេលនោះ ពិតជាមានសារៈសំខាន់ចំពោះការផ្លាស់ប្ដូរ ចែករំលែកបទពិសោធន៍ ផ្ដល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក ហើយក៏ជាព្រឹត្តិការណ៍មួយនៅក្នុងចំណោមព្រឹត្តិការណ៍ដ៏ឱឡារិក និងធំៗជាច្រើនទៀត ដែលប្រទេសទាំងពីរបានរៀបចំ ដើម្បីប្រារព្ធការអបអរសាទរខួបលើកទី៥៥ឆ្នាំ នៃការបង្កើតទំនាក់ទំនងការទូត និងជាឆ្នាំមិត្តភាព នៃប្រទេស និងប្រជាជនទាំងពីរ។

លោកជំទាវ **មាន សំអាន** មានជំនឿជឿជាក់ថា ទំនាក់ទំនងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិការរវាងប្រជាជន នៃប្រទេសទាំងពីរកាន់តែរឹងមាំ ស្ថិតស្ថេរ ពុំមានកម្លាំងអមិត្តណាអាចបំបែកបំបាក់បានឡើយ។ កម្ពុជា-វៀតណាម គឺអ្នកជិតខាងល្អ មិត្តល្អ បងប្អូនល្អ និងដៃគូល្អ។ ឈានចូលដល់ដំណាក់កាលថ្មីនេះ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរឈានឡើងកម្រិតទំនាក់ទំនងមិត្តភាពអ្នកជិតខាងល្អជាប្រពៃណី និងប្រកបដោយសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ រឹងមាំ យូរអង្វែង និងគ្រប់វិស័យ។

នាល្ងាចថ្ងៃដដែលនោះ គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញចូលជួបសម្ដែងការគួរសមឯកឧត្តម **ង្វៀន វ៉ាន់ក្វាង** លេខាគណៈកម្មាធិការបក្សទីក្រុងដាណាំង និងចូលរួមពិធីលៀងសាយភោជន៍ ដែលរៀបចំដោយឯកឧត្តមលេខាគណៈកម្មាធិការបក្សទីក្រុងដាណាំង នៅសណ្ឋាគារ Nalod។

ដោយឡែកនាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូក្រុមមិត្តភាពព្រឹទ្ធសភាជាមួយនឹងរដ្ឋសភាវៀតណាម បានអញ្ជើញជួបសម្ដែងការគួរសមជាមួយនឹងឯកឧត្តម **លឿង ង្វៀន មីញត្រៀត** ប្រធានក្រុមប្រឹក្សាភិបាលទីក្រុងដាណាង នៅសាលាក្រុងដាណាង ខេត្តក្វាងណាម ប្រទេសវៀតណាម។ បន្ទាប់មកគណៈប្រតិភូបានអញ្ជើញទស្សនកិច្ចក្រុមហ៊ុន HOA THO ពីវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ នៅតំបន់សេដ្ឋកិច្ច ទីក្រុងដាណាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*លោកជំទាវ មាន សំអាន និងឯកឧត្តម លឿង ង្វៀន មីញត្រៀត*




*លោកជំទាវ មាន សំអាន ថតរូបអនុស្សាវរីយជាមួយឯកឧត្តម លឿង ង្វៀន មីញត្រៀត*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❋ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រីការិយាល័យអមក្រុមភូមិភាគទី៨ ស្ដីពីការត្រៀមរៀបចំជំនួបពិភាក្សាការងារជាមួយនឹងក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ និងការត្រៀមរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សជាតិ ១០ធ្នូ ខួបលើកទី៧៤ ឆ្នាំ២០២២ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។

-ដឹកនាំកិច្ចប្រជុំជាមួយនឹងមន្ត្រីលេខាធិការដ្ឋានអមគណៈកម្មការទី១ព្រឹទ្ធសភា និងមន្ត្រី នៃនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីត្រៀមរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ១០ធ្នូ ដែលគ្រោងនឹងប្រព្រឹត្តទៅនាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា នាថ្ងៃទី១ និងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា។



-ទទួលជួបពិភាក្សាការងារជាមួយនឹងលោកជំទាវ **ស្រី គឹមឆយ** សមាជិកាគណៈកម្មការទី១រដ្ឋសភា ស្ដីពីការត្រៀមរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ១០ធ្នូ ខួបលើកទី៧៤ ក្រោមប្រធានបទ “ខួបលើកទី៧៥នៃសេចក្ដីប្រកាសសកលស្ដីពីសិទ្ធិមនុស្ស” នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២។

❋នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានប្រជុំពិគ្រោះយោបល់ស្ដីពី ការបង្កើតគណៈកម្មការពិសេស និងនីតិវិធីការងារ ដើម្បីរៀបចំ



សេចក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស វិមានព្រឹទ្ធសភា។

❋ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ស្ដាប់បទបង្ហាញមន្ត្រីជំនាញ នៃនាយកដ្ឋានស្រាវជ្រាវថវិកា ស្ដីពីសេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ និងសេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិភាក្សាលើ៖

១-ស្ថានភាពថវិការបស់គណៈកម្មការ

២-ពិភាក្សាការងារចំពោះមុខរបស់គណៈកម្មការ និងចន្លោះសម័យប្រជុំព្រឹទ្ធសភា ទី៩ និងទី១០

៣-បញ្ហាផ្សេងៗ។

-ដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការទី២ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ និងសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅសាលសិក្ខាសាលា-ខាងជើង វិមានព្រឹទ្ធសភា នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២។



-ដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក) នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរ-ជាតិ។

❈នាព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត



**ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា នៅសាលប្រជុំគណៈ-កម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សាលើ៖

១-ការបូកសរុបលទ្ធផលការងារ និងការអនុវត្តថវិការបស់គណៈកម្មការប្រចាំឆ្នាំ២០២២

២- ពិនិត្យ និងសម្រេចលើផែនការប្រតិបត្តិរបស់គណៈ-កម្មការប្រចាំឆ្នាំ២០២៣

៣- បញ្ហាផ្សេងៗ។



❈នាព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) នៅសាលប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក) នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិល

អន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥៦ នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរ-ជាតិ។



❈នារសៀលថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវកិត្តិ-នីតិកោសលបណ្ឌិត **ឌី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងាររបស់គណៈកម្មការប្រចាំខែវិច្ឆិកា

២-ការរាយការណ៍បឋមអំពីដំណើរការលិខិតបេសកកម្មទៅក្រសួងមហាផ្ទៃ របស់គណៈកម្មការចុះបេសកកម្មនៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

៣-ការរាយការណ៍អំពីថវិកាសម្រាប់ចុះបេសកកម្មនៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

៤-បញ្ហាផ្សេងៗ។

❈ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖



-គណៈកម្មការទី៦ព្រឹទ្ធសភា អំពីការពិនិត្យពិភាក្សាលើសេចក្ដីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣ និងការងារផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២។

-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើសេចក្ដីព្រាង-ច្បាប់ចំនួន៣គឺ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្ដីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥០(ក) នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥៦ នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរ-ជាតិ។



❈ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដើម្បីពិនិត្យពិភាក្សាលើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

២-សេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញា

ស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥០(ក) នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

-ដឹកនាំកិច្ចប្រជុំក្រុមសភាជាតិកម្ពុជា-APF នៃព្រឹទ្ធសភា ត្រៀមរៀបចំខ្លឹមសារ និងឯកសារពាក់ព័ន្ធនានា ដើម្បីទទួលគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើប្រាស់ភាសាបារាំង ដែលគ្រោងមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។



-ជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង (APF) ដឹកនាំដោយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង (APF) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២។




-ទទួលគ្រឿងឥស្សរិយយស Odre de la Pleiade (Grade de Commandeur) ពីសភាប្រើប្រាស់ភាសាបារាំង ដែលបំពាក់ដោយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង (APF) នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២។

❋ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

-គណៈកម្មការទី៩ព្រឹទ្ធសភា នៅសាលប្រជុំគណៈកម្មការទី៩ព្រឹទ្ធសភា នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

**១**-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន

**២**-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០ (ក) នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

**៣**-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

-ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា នារសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

**១**-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

**២**-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

**៣**-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥០(ក) នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា ៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

-គណៈកម្មការនានារបស់ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖



១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្ដីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន
២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០ (ក) នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ
៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

-គណៈកម្មការទី៩ព្រឹទ្ធសភា នៅសាលប្រជុំពិសេសព្រឹទ្ធសភា នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងពិភាក្សាជាលើកចុងក្រោយ លើសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញាស្ដីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣ស្ទួន
២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០ (ក)នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ
៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្ដីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

❈នារសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងារ ព្រមទាំងរបាយការណ៍ថវិការបស់គណៈ-កម្មការប្រចាំខែធ្នូ ឆ្នាំ២០២២ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាដឹកនាំដោយឯកឧត្តម **កែវ រ៉េមី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីពិគ្រោះយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសិទ្ធិមនុស្ស នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

❈ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធ-សភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី១០ នៃសភាប្រើប្រាស់ភាសាបារាំង-APF តំបន់អាស៊ី-ប៉ាស៊ីហ្វិក ដឹកនាំដោយឯកឧត្តម **កែប ជុតិមា** ប្រធានគណៈកម្មការទី៤ រដ្ឋសភា និងជាសមាជិកក្រុមសភាជាតិកម្ពុជា-APF នៅទីក្រុងដាណាង ប្រទេសវៀតណាម៕



# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលអញ្ជើញមកទស្សនាសួនសត្វ ព្រមទាំងចុះដឹកនាំក្រុមការងារគ្រឿងចក្រសាងសង់សហចេតិយ រោងបុណ្យ និងកែលម្អសួនសត្វឱ្យមានសោភ័ណភាព ព្រមទាំងផាសុកភាពសត្វប្រសើរឡើងវិញ ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនាកម្សាន្ត នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកទស្សនាសហចេតិយដែលអាចតម្កល់ធាតុប្រមាណជា២.០០០កោដ្ឋ ដែលបានស្ថាបនាជិតរួចរាល់ជាស្ថាពរ នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ម៉ុង ឬទ្ធីសែនជ័យ ស្ថិតក្នុងភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងដឹកនាំក្រុមការងារគ្រឿងចក្រសាងសង់ទំនប់ទឹកថ្មីមានបណ្ដោយ ៣៥០x១៥០ម៉ែត្រ ដើម្បីស្ដុកទឹកទុកប្រើប្រាស់ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសសំណង់ និងកសិកម្ម ពិនិត្យមើលសមិទ្ធផលនានាដែលបានសាងសង់ជិតរួចរាល់ស្ថាពរ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកសៀវភៅ និងថវិកាមួយចំនួនចែកជូនកម្មករធ្វើការនៅចម្ការកៅស៊ូ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២។



-នាំកម្មករចម្ការដូងប្រេង រួមជាមួយនឹងអាជ្ញាធរដែនដីដឹកនាំដោយឯកឧត្តម **គួច ចំរើន** អភិបាល នៃគណៈ-អភិបាលខេត្តព្រះសីហនុ ព្រមទាំងមន្ត្រីរាជការក្រោមឱវាទ ប្រជាពលរដ្ឋ ភ្ញៀវជាតិ និងអន្តរជាតិចូលរួមដាំដើមកោង-កាង នៅលើផ្ទៃដីទំហំប្រមាណជា៣ហិកតា នៅក្នុងតំបន់ចម្ការដូងប្រេង នៅភូមិតាពៅ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលរោងចក្រផលិតចំណីសត្វ ហេដ្ឋារចនាសម្ព័ន្ធនានា និងពិនិត្យមើលទំនប់ទឹក ដើម្បីស្ដុកទឹកទុកប្រើប្រាស់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២។



❈នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **ឆាយ ឋណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ហេង ម៉ូរ៉ា** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីអបអរសាទរការប្រកាសខេត្តត្បូងឃ្មុំអស់មីន ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពល-ខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលាខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុម-ប្រឹក្សាសង្កាត់កន្ទោក ដើម្បីស្ដាប់របាយការណ៍រួមក្នុងមូល-ដ្ឋាន ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នៅខណ្ឌកំបូល



រាជធានីភ្នំពេញ។



❈នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ឌីមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងគណៈគ្រប់គ្រងសាលារៀន ព្រមទាំងឧបត្ថម្ភនូវថវិកាមួយចំនួន នៅសង្កាត់កន្ទោក សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះរស់នៅភូមិអំពិលក្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង។



❈រសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ម៉ុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយរបស់ក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ចែកជូនដល់ក្មួយៗពិការភាពសតិបញ្ញា និងអូទីស្សឹម ចំនួន ២១៥នាក់ និងលោកគ្រូ អ្នកគ្រូចំនួន៥៨នាក់ នៅវិទ្យាល័យអប់រំពិសេសក្រុងតាខ្មៅ ខេត្តកណ្ដាល។

❈ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំខេត្តពោធិ៍សាត់ នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២។



-ចូលរួមពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវលេខ ១៤៦បេ (វិថីសម្ដេចសង្ឃរាជ ទេព វង្ស) និងផ្លូវលេខ១៤៨ (តីរវិថីសម្ដេចតេជោ ហ៊ុន សែន) ប្រវែងសរុប៤៣,០២៥ គ.ម. នៅខេត្តព្រះសីហនុ ដោយប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត នៅភូមិវាលធំ ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

❈ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២ ។

-ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានានៅក្នុងវត្តបុរាណ និវេសន៍ ហៅវត្តប្រាសាទនាងខ្មៅ ស្ថិតនៅភូមិចារ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២។

❈ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការ

ទី៣ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈ-កម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាល និងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសិក្សានៅវិទ្យា-ល័យបវេល វិទ្យាល័យព្រៃល្វា និងសាលាបឋមសិក្សាព្រៃ-ស្វាយ ព្រមទាំងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់-ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជួបសំណេះ-សំណាលសួរសុខទុក្ខដល់ក្រុមប្រឹក្សាឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២២។

-ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះបឋមសិលាសាងសង់វិមានឯករាជ្យ សួនសម្ដេចក្រឡាហោម និងផ្សាររាត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នាថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០២២។

❈នាថ្ងៃទី១២ ថ្ងៃទី១៣ និងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អាយ ខន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធ-សភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុម-ប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅស្រុកបុទុម-សាគរ ស្រុកគិរីសាគរ ខេត្តកោះកុង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខលោក **សូ ដា** ប្រធានក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលកំពុងសម្រាកថែទាំសុខភាពនៅគេហដ្ឋាន នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមទទួលអំណោយសប្បុរសធម៌ជាទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួន ដើម្បីជួយទ្រទ្រង់សកម្មភាពចិញ្ចឹម ថែទាំ ព្យាបាលសុខភាព ស្តារនីតិ-សម្បទា ព្យាបាលជំងឺ អប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីអប់រំឱវាទចរិយាធម៌ សីលធម៌ ដល់យុវជន យុវនារីរងគ្រោះដោយសារគ្រឿងញៀន ពីព្រះអនុគណ នៅខណ្ឌដង្កោ រាជធានីភ្នំពេញ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២។





-ជួបសំណេះសំណាលជាមួយនឹងមន្ត្រីផ្នែកអនាម័យ និងផ្នែកសន្តិសុខ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅគណៈកម្មការទី៧ព្រឹទ្ធសភា នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងបងប្អូនប្រជាពលរដ្ឋ និងជួយឧបត្ថម្ភសម្រាលការលំបាកខ្វះខាតជូនក្រុមគ្រួសារក្រីក្រ-ក១ ក្រីក្រ-ក២ និងគ្រួសារដែលងាយរងគ្រោះ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា



បានអញ្ជើញនាំយកអំណោយ និងថវិកាមួយចំនួនចូលរួមពិធីបុណ្យសពកុមារា កុមារីចំនួន៤នាក់ ដែលបានលង់ទឹកស្លាប់ កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ នៅចំណុចភូមិព្រៃសំរោង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល។

❈ឯកឧត្ដម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងចូលរួមរំលែកទុក្ខក្រុមគ្រួសារ នៃសព៥គ្រួសារ និងទិញម៉ាស៊ីនព្រីនធ័រ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាលពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងចូលរួមរំលែកទុក្ខក្រុមគ្រួសារ នៃសពនូវបច្ច័យមួយចំនួន និងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២។

❈ឯកឧត្ដម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវកៅស៊ូ DBST ប្រវែង១៦គីឡូម៉ែត្រ ក្រោមអធិបតីភាពឯកឧត្ដម **ហ៊ុន ម៉ានី** តំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមក្នុងពិធីបុណ្យសពលោក **ម៉ែន នឿន** អតីតប្រធានក្រុមប្រឹក្សាស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងចូលបច្ច័យបុណ្យមួយចំនួន នៅភូមិឃ្លៃចាស់ ឃុំពោធិ៍ចំរើន ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២។

❈នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្ដម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

❈ឯកឧត្ដម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរឃុំបាសាក់ ដើម្បីឈ្វេងយល់អំពីកិច្ចការអភិវឌ្ឍ សន្តិសុខ ការពិនិត្យឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ព្រមទាំងក្ដីកង្វល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ ស្ថិតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្ដម **ហ៊ាន ឿន** ទីប្រឹក្សាក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាអតីតសមាជិកក្រុមប្រឹក្សាខេត្តស្វាយរៀង នៅខេត្តស្វាយរៀងនាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំកំពង់ចម្លង ឃុំចំបក់ និងឃុំគ្រួស ក្នុងពិធីអបអរសាទរទិវាសិទ្ធិមនុស្ស ដោយប្រែក្លាយជាការដាំកូនឈើចំនួនជាង២.០០០ដើម តាមទំនប់ព្រំដែនកម្ពុជា វៀតណាម ដើម្បីបង្កើនបរិស្ថានកាន់តែស្រស់បំព្រង ស្ថិតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងព្រះសង្ឃក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍៤៨ឆ្នាំ នៅថ្ងៃបង្កើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅសង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២។



❈នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្ដម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកម្មវិធីសំណេះសំណាលជាមួយនឹងមនុស្សចាស់ ជនពិការ និងអតីតយុទ្ធជន ក្រោមអធិបតីភាពឯកឧត្ដមនាយឧត្ដមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅភូមិបឹងជង្រុកតេជោឈ្នះ-ឈ្នះ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

❈នាថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០២២ ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញនាំយកថវិកាមួយចំនួនសម្រាប់ឧបត្ថម្ភជូនភ្នាក់ងារសង្កេតការណ៍ និងពិនិត្យការចុះឈ្មោះបោះឆ្នោត នៅឃុំត្រពាំងគរ ព្រមទាំងចូលបច្ច័យមួយចំនួនក្នុងពិធីបុណ្យសព នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈ឯកឧត្តម **ញ៉ៀប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកចង្ហាន់បិណ្ឌបាត ទេយ្យទាន គ្រឿងឧបភោគ និងបច្ច័យប្រគេនព្រះសង្ឃដែលគង់នៅវត្តពោធិ៍សុវណ្ណរង្សី ស្ថិតក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២២។

-ចូលរួមពិធីបួងសួងនៅបូជនីយដ្ឋានឧកញ៉ាឃ្លាំងមឿង ដើម្បីសុំសេចក្តីសុខចម្រើនដល់ប្រជាជនខេត្តពោធិ៍សាត់ និងទូទាំងប្រទេសកម្ពុជា នៅខេត្តពោធិ៍សាត់ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងឧបត្ថម្ភប្រជាពលរដ្ឋក្រីក្រចំនួន៤០០គ្រួសារ ដោយក្នុងមួយគ្រួសារៗទទួលបាន៖ អង្ករ២៥គីឡូក្រាម មី១កេស ទឹកស៊ីអ៊ីវ១យួរ ទឹកត្រី១យួរ និងត្រីខ១យួរ នៅវត្តទួលរកា ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។

-ជួបសំណេះសំណាល និងសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយចែកជូនប្រជាពលរដ្ឋចំនួន៣៥៣នាក់ ដោយក្នុងមួយគ្រួសារទទួលបាន អង្ករ៥គីឡូក្រាម មី ស្ករ ទឹកដោះគោ និងប្រេងឆា នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០២២ ។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងសិស្សានុសិស្សត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិ (បាក់ឌុប) ឆ្នាំសិក្សា ២០២២ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅសាលសន្និសីទបូកគោ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសម្ពោធសមិទ្ធផលនានានៅវត្តបុរាណនិវេសន៍ហៅវត្តប្រាសាទនាងខ្មៅ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯកបណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិចារ ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។

❈នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **សៀង ណាំ** តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប នៅខេត្តសៀមរាប។

❈នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **ម្លូង ម៉យ** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ នៅភូមិគួង ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី។

❈លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ខា ចាន់តូ** សមាជិកក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី



១ ខែធ្នូ ឆ្នាំ២០២២។



-ជួបសំណេះសំណាលជាមួយនឹងក្មួយៗសិស្សានុសិស្សក្រីក្រចំនួន១៤នាក់ មកពីវិទ្យាល័យត្បែង និងវិទ្យាល័យទួលក្បិលដែលនឹងត្រៀមប្រឡងសញ្ញាបត្រទុតិយភូមិនាពេលខាងមុខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ក្មួយៗទាំង១៤នាក់ មាតាបិតាសិស្សទាំង១៤នាក់ លោកនាយក-សាលា និងលោកគ្រូចំនួន៦នាក់ ដែលក្នុងម្នាក់ៗទទួលបានក្រមា១ នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នារសៀលថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។



-ជាអធិបតីភាពក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៤៤ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (២ធ្នូ ១៩៧៨-២ធ្នូ ២០២២) នៅបរិវេណពហុកីឡដ្ឋានខេត្តកំពង់ធំ នារសៀលថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២។



-សហការជាមួយនឹងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃបេសក-កម្មមនុស្សធម៌ (AMH) នៃប្រទេសបារាំងកម្ពុជារបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខន** អនុប្រធានទី២ព្រឹទ្ធសភា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងបរិវេណសាលាឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២។

❈នាថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធអគារវិទ្យាល័យជ្រៃ ចំនួន១ខ្នង មាន២ជាន់ ចំនួន១២បន្ទប់ ក្រោមអធិបតីភាពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅភូមិក្បាលខ្មោច ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

❈នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជាអធិ-បតីភាពក្នុងពិធីសំណេះសំណាលជាមួយនឹងអាជ្ញាធរស្រុកត្រពាំងប្រាសាទ ស្តីពីវិធានការពង្រឹងការគ្រប់គ្រងការងារភូមិ ឃុំ មានសុវត្ថិភាព ការងារផ្តល់សេវាជូនប្រជាពលរដ្ឋ ការជំរុញប្រជាពលរដ្ឋឱ្យទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោត និងការដោះស្រាយសំណូមពរប្រជាពលរដ្ឋ ព្រមទាំងចុះទៅប្រគល់ផ្ទះមួយខ្នងជូនលោក **ឡុន ឆួន** និងភរិយា **ចែម សួរ** ជាគ្រួសារក្រីក្រ និងចូលរួមបុណ្យសពលោក **ធិន ឆុន** អាយុ៥៧ឆ្នាំ ស្ថិតនៅភូមិសែនសំ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

❈នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា



បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ទោ **នូ សុផល** អតីតនគរបាលខេត្តសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖




-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ មេប៉ុស្តិ៍រដ្ឋបាល ប្រធានមណ្ឌលសុខភាព ស្មៀន ប្រធានភូមិ ដើម្បីឈ្វេងយល់ពីសភាពការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួម និងសម្រាប់មូលនិធិសង្គហធម៌ឃុំ នៅសាលាឃុំពាមឆ្កោក ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ មេប៉ុស្តិ៍រដ្ឋបាល ប្រធានមណ្ឌលសុខភាព ស្មៀន ប្រធានភូមិ



ដើម្បីឈ្វេងយល់ពីសភាពការរួមក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួម សម្រាប់មូលនិធិសង្គហធម៌ឃុំ ចូលរួមជួយចេញថ្លៃចាក់ដី និងផ្ដល់កំព្យូទ័រយួរដៃ១គ្រឿង ស្ថិតនៅសាលាឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នារសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។

❈នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំចំនួន១៥រូប ដើម្បីតាមដាន និងជំរុញសកម្មភាពការងារឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ២០២៣ នាពេលខាងមុខ នៅស្រុកអង្គរធំ ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកបច្ច័យមួយចំនួនប្រគេនដល់ព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសា ដើម្បីកសាងផ្លូវក្នុងបរិវេណវត្ត ស្ថិតនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួន ដើម្បីឧបត្ថម្ភដល់កាកបាទក្រហមខេត្តសៀមរាប នាព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២៕

## ការទទួលពាក្យបណ្ដឹង

❈នៅខែធ្នូ ឆ្នាំ២០២២ ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៩ករណី (សល់ពីខែមុន៦ករណី) ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្ដឹងពីក្រសួងការពារជាតិចំនួន១ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន៧ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន១១រូប បានអញ្ជើញចូលរួមព្រឹត្តិការណ៍បិទការប្រកួតកីឡាជាតិលើកទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ។



❈នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមមីទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (២ធ្នូ ១៩៧៨ - ២ធ្នូ ២០២២) ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលសន្និសីទចតុមុខ។



❈នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ គណៈកម្មការទី១ព្រឹទ្ធសភា និងគណៈកម្មការទី១រដ្ឋសភា បានសហការរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ខួបលើកទី៧៤ ឆ្នាំ២០២២ ក្រោមប្រធានបទ "ខួបលើកទី៧៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា នៅសាលសិក្ខាសាលាបណ្ណាល័យវិមានព្រឹទ្ធសភា។

❈នាថ្ងៃទី៩ និងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ សមាជិកព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមពិធីបើកជាផ្លូវការពិធីបុណ្យសមុទ្រលើកទី៩ ជុំទី៣ ឆ្នាំ២០២២ ក្រោមប្រធានបទ "ឆ្នេរនៃសន្តិភាពឆ្នេរ នៃក្តីសង្ឃឹម (Bay of Peace, Bay of Hope)" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅបរិវេណទីលានតេជោ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។




❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាជនមានពិការភាពកម្ពុជាលើកទី២៤ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៤០ ក្រោមប្រធានបទ "ពិការភាពទាំងអស់មិនអាចកំណត់ដោយការមើលនឹងភ្នែកនោះទេ" ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង

អធិការកិច្ច នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២។

❃ឯកឧត្តមបណ្ឌិត **ម៉ុខ ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបាន៖



-អនុញ្ញាតឱ្យឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណៈរដ្ឋឥស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបពិភាក្សាការងារគ្រប់គ្រងរបស់គណៈកម្មការទី៣ព្រឹទ្ធសភា និងការងារពាក់ព័ន្ធលើវិស័យកសិកម្ម នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា នារសៀលថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២។



-អញ្ជើញចូលរួមពិធីជប់លៀងបញ្ចប់អាណត្តិជូនឯកឧត្តម Mikami Masahiro ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២។

-អញ្ជើញចូលរួមពិធីសម្ពោធបន្ទប់ពិគ្រោះជំងឺផ្លូវចិត្ត នៅបុរីជីបម៉ុង ផ្លូវជាសុផារ៉ា រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២។



-អនុញ្ញាតឱ្យប្រធានសម្ព័ន្ធសភាកូរ៉េ ស្ដីពីកុមារ ប្រជាជន និងបរិស្ថាន នៃសាធារណរដ្ឋកូរ៉េ ចូលជួបពិភាក្សាការងារ នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។

❃ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖



-ទទួលស្វាគមន៍ ឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង-APF នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២។



-រៀបចំពិធីពិសាអាហារការងារជាមួយនឹងគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង-APF ដឹកនាំ

ដោយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយ នៃសភាប្រើភាសាបារាំង-APF នៅសណ្ឋាគារ Palace Gete Hotel រាជធានីភ្នំពេញ នាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២២។



-ជូនដំណើរគណៈប្រតិភូបេសកកម្មសុឆន្ទៈ នៃសភាប្រើភាសាបារាំង-APF ធ្វើមាតុភូមិនិវត្តន៍ទៅកាន់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២២។



❈នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ស្ថិតនៅគេហដ្ឋាន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

❈រសៀលថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលសួរសុខទុក្ខឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនរបស់គណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីឧបត្ថម្ភកម្មវិធីទិវាជនមានពិការភាពកម្ពុជាលើកទី២៤ និងអន្តរជាតិលើកទី៤០ (៣ធ្នូ ឆ្នាំ២០២២) នារសៀលថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួនរបស់គណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីឧបត្ថម្ភជូនមន្ទីរពេទ្យគន្ធបុប្ផាតាមរយៈគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២។



-ជាគណៈអធិបតីភាពក្នុងពិធីអបអរសាទរទិវាជាតិ-អន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ ៩ធ្នូ ក្រោមអធិបតីភាពឯកឧត្តម **តុប សំ** ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ នៅសាលសហព័ន្ធកីឡាការ៉ាតេកម្ពុជា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នារសៀលថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២។

❈នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ជាមួយនឹងគណៈប្រតិភូបេសកកម្ម-

សុឆន្ទៈ នៃសភាប្រើភាសាបារាំង-APF ក្រោមការទទួលស្វាគមន៍ពីលោកជំទាវ **ស៊ុន សារឿន** សមាជិកគណៈ-កម្មការទី៥រដ្ឋសភា នៅភោជនីយដ្ឋានខេម៉ា រាជធានី-ភ្នំពេញ។

❈នាព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា លើកទី៨ នីតិកាលទី៦ ស្តីពី “ការបូកសរុបលទ្ធផល និងវាយតម្លៃការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានអាយ-ប៉ាលើកទី៤៣ (AIPA-43)” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានមហា-សន្និបាតអន្តរសភាអាស៊ានលើកទី៤៣ នៅវិមានរដ្ឋសភា។



❈នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរទិវាជាតិ ១២ធ្នូ ប្រឆាំងការជួញដូរមនុស្សឆ្នាំ២០២២ ក្រោមប្រធានបទ “រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្សឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈ-មណ្ឌលកោះពេជ្រ។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យទក្ខិនានុប្បទាន៧ថ្ងៃឧបាសិកា **លីវ យីន** ម្តាយក្មេក ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា នៅផ្លូវជាតិ៦A រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។

❈នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមព្រះរាជពិធីបុណ្យសម្ពោធមណ្ឌលព្រះកម្មដ្ឋាន “ព្រះករុណាព្រះមហាក្សត្រសីហមុនី” ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់-ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណា-ចក្រកម្ពុជា។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្ម-ការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យសពឧបាសិកា **ផន យ៉ុន** បងស្រីបង្កើតរបស់ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងបាននាំយកថវិកាមួយចំនួនរបស់គណៈ-កម្មការទី១០ព្រឹទ្ធសភា ដើម្បីចូលបុណ្យ ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២២។

-នាំយកថវិកាមួយចំនួន ដើម្បីឧបត្ថម្ភជូនមន្ទីរពេទ្យគន្ធបុប្ផាតាមរយៈគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងកំណត់ទិសដៅការងារខែធ្នូ ឆ្នាំ២០២២



*ឯកឧត្តម អ៊ុំ សារឹទ្ធ (ឆ្វេង) និងឯកឧត្តម លឹម ប៊ុនហុក (ស្ដាំ)*

នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា និងលើកទិសដៅការងារសម្រាប់ខែធ្នូ ឆ្នាំ២០២២ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធានប្រធាននាយកដ្ឋានឡើង។

កិច្ចប្រជុំបានដំណើរការតាមកម្មវិធី ដោយមានការបញ្ចាំងវីដេអូបូកសរុបលទ្ធផលការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០២២ និងកិច្ចពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍ការងារ បញ្ហាប្រឈម សំណូមពរ និងមតិបូកសរុបរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានជម្រាបជូនអង្គប្រជុំអំពី សភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែវិច្ឆិកាថា ព្រឹទ្ធសភា និងប្រជាជនកម្ពុជាទូទាំងប្រទេសបានចូលរួមអបអរសាទរ និងសម្ដែងការសប្បាយរីករាយដែលព្រះរាជាណាចក្រកម្ពុជាទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣។ ស្ថិតក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក៏បានផ្ដោតការយកចិត្តទុកដាក់ផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភាជួបសវនាការជាមួយនឹងគណៈប្រតិភូជាន់ខ្ពស់បណ្ដាប្រទេសនានា ព្រមទាំងចូលរួមកិច្ចប្រជុំអន្តរជាតិបានល្អប្រសើរ ជាពិសេសការរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចូលរួមក្នុងមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

សម្រាប់ខែចុងក្រោយ នៃឆ្នាំ២០២២នេះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់អង្គភាពចំណុះទាំងអស់ត្រូវបន្តធានាបរិមាណ និងគុណភាពក្នុងការផ្ដល់សេវាឱ្យកាន់តែល្អប្រសើរ និងទាន់ពេលវេលាជូនដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញជាពិសេសវិធានការ “៣ការពារ ៣កុំ” និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារកុំឱ្យឆ្លងជំងឺកូវីដ-១៩ រាលដាលជាថ្មីទៀតបាន៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះអនុស្សរណៈយោគយល់គ្នា ជាមួយវិទ្យាស្ថានស្រាវជ្រាវ KING PRAJADHIPOK



ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាជាមួយវិទ្យាស្ថាន KPI

នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្តមសាស្ត្រាចារ្យ Woothisarn Tanchai អគ្គលេខាធិការវិទ្យាស្ថានស្រាវជ្រាវ KING PRAJADHIPOK បានអញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពី កម្មវិធីសហប្រតិបត្តិការរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ជាមួយនឹងវិទ្យាស្ថានស្រាវជ្រាវ KPI (KING PRAJADHIPOK INSTITUTION) នៃព្រះរាជាណាចក្រថៃ នៅសាលប្រជុំពិសេសIII វិមានព្រឹទ្ធសភា។

ក្នុងនាមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងវាយតម្លៃខ្ពស់ចំពោះការបន្តសហប្រតិបត្តិការលើការងារស្រាវជ្រាវរវាងអគ្គលេខាធិការវិទ្យាស្ថាន KPI (KING PRAJADHIPOK INSTITUTION) ជាមួយនឹងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ដើម្បីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរក្នុងការបម្រើសេវាស្រាវជ្រាវគ្រប់ផ្នែកជូនសភា ព្រមទាំងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងប្រជាធិបតេយ្យ និងចែករំលែកគ្នាទៅវិញទៅមកអំពីវប្បធម៌ នៃប្រទេសទាំងពីរ។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាមានជំនឿជឿជាក់ថា កិច្ចសហប្រតិបត្តិការនេះនឹងរួមចំណែកលើកកម្ពស់សមត្ថភាពជំនាញ ចំណេះដឹង និងចំណេះធ្វើរបស់មន្ត្រីស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការបម្រើសេវាស្រាវជ្រាវព័ត៌មាន និងឯកសារជូនព្រឹទ្ធសភា។ ជាងនេះទៅទៀត ការចុះអនុស្សរណៈយោគយល់គ្នានេះ នឹងរួមវិភាគទានដល់ការគាំទ្រព្រឹទ្ធសភាកម្ពុជា ក្នុងការអនុវត្តមុខងារស្នូលទាំងបីរបស់ខ្លួន រួមមាន៖ មុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់ ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។

ក្នុងឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្តមសាស្ត្រាចារ្យ Woothisarn Tanchai អគ្គលេខាធិការវិទ្យាស្ថាន KPI បានសម្តែងនូវសេចក្តីរីករាយយ៉ាងក្រៃលែង ដែលបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ក្នុងការផ្ទេរនូវចំណេះដឹងទៅវិញទៅមកក្នុងការបម្រើសេវាជូនសភា នៃប្រទេសទាំងពីរឱ្យក្លាយទៅជាប្រទេសដែលមានភាពជឿនលឿន។

សូមជម្រាបថា ការចុះអនុស្សរណៈយោគយល់គ្នានេះ មានគោលបំណងបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរបទពិសោធន៍លើការងារស្រាវជ្រាវរវាងវិទ្យាស្ថាន KPI នៃព្រះរាជាណាចក្រថៃ និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា ដែលមានរយៈពេល៣ឆ្នាំ (២០២២-២០២៥) ដើម្បីលើកកម្ពស់សេវាស្រាវជ្រាវរបស់ស្ថាប័នទាំងពីរឱ្យកាន់តែមានគុណភាពខ្ពស់ថែមទៀត៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ ធុន គីមជី)




អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចុះអនុស្សរណៈជាមួយវិទ្យាស្ថាន KPI

# ថ្នាក់ដឹកនាំ គ្រប់គ្រងអង្គភាពចំណុះអ.ពស ត្រូវបានពង្រឹងសមត្ថភាព លើជំនាញការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ



ឯកឧត្តម អ៊ុំ សារឹទ្ធ អគ្គលេខាធិការព្រឹទ្ធសភា

នាព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ សម្រាប់ថ្នាក់ដឹកនាំគ្រប់គ្រងអង្គភាពចាប់ពីប្រធាននាយកដ្ឋានឡើងចំនួន៤៤នាក់។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

មានប្រសាសន៍ក្នុងឱកាសបិទវគ្គបណ្ដុះបណ្ដាលឯកឧត្តម **អ៊ុំ សារឹទ្ធ** បានវាយតម្លៃខ្ពស់ចំពោះការចូលរួមរបស់ថ្នាក់ដឹកនាំ គ្រប់គ្រងដែលធ្វើឱ្យវគ្គបណ្ដុះបណ្ដាលនេះប្រព្រឹត្តទៅដោយរលូន និងទទួលបានផ្លែផ្កា។ ជាមួយគ្នានេះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានថ្លែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំ គ្រប់គ្រងអង្គភាពទាំងអស់ ដែលបានផ្លាស់ប្ដូរបទពិសោធន៍ល្អៗ ចែករំលែកព័ត៌មាន និងផ្លាស់ប្ដូរគំនិតគ្នាទៅវិញទៅមកលើការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ដោយទទួលបានលទ្ធផលយ៉ាងល្អ។ តាមរយៈការផ្លាស់ប្ដូរបទពិសោធន៍ ចំណេះដឹងថ្មីៗ និងការចែករំលែកព័ត៌មានគ្នានេះ បានរកឃើញនូវបញ្ហាមួយចំនួនដែលអាចដោះស្រាយរួម ដើម្បីការអភិវឌ្ឍស្ថាប័ន។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាសង្ឃឹមថា បន្ទាប់ពីបញ្ចប់វគ្គបណ្ដុះបណ្ដាលនេះទៅ សូមថ្នាក់ដឹកនាំ គ្រប់គ្រងទាំងអស់បន្តចែករំលែកគំនិតទ្រឹស្ដីសំខាន់ៗ ចំណេះដឹង និងបទពិសោធន៍ល្អៗទៅដល់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីជាការបន្តវេនទៅថ្ងៃខាងមុខទៀត។

សូមជម្រាបថា វគ្គបណ្ដុះបណ្ដាលនេះប្រព្រឹត្តទៅរយៈពេល៥ពេល សិក្សារៀងរាល់ព្រឹកចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ឧទ្ទេសនាមដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ព្រមទាំងមានការឡើងធ្វើបទបង្ហាញអំពីការស្រាវជ្រាវប្រធានបទនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ពីតំណាងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៕

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ គង់យ៉ារីន)



ទិដ្ឋភាពក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាល

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃសៅរ៍ ទី៣ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាថ្ងៃចន្ទ ទី៥ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោក Gibert Palaoro អតីតទទួលបន្ទុកទីភ្នាក់ងារឧត្តមសិក្សា នៃសាកលវិទ្យាល័យប្រើភាសាបារាំង ចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២ គណៈកម្មការពិនិត្យវាយតម្លៃសមត្ថភាពមន្ត្រីរាជការ ដើម្បីតែងតាំងមុខតំណែងក្នុងអង្គការលេខ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំការងារជាមួយអង្គភាពកិច្ចការសង្គម ដើម្បីពិនិត្យការអនុវត្តការងារតាមតួនាទី ភារកិច្ចរបស់អង្គភាពកិច្ចការសង្គម នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំពិនិត្យលើការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្នុងការផ្ដល់សេវាជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យកាន់តែប្រសើរ នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ











❈នាព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់ថ្នាក់ដឹកនាំអង្គភាពចាប់ពីប្រធាននាយកដ្ឋានឡើង នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារអមគណៈកម្មការពិសេស បានប្រជុំក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សា រៀបចំសេចក្តីព្រាងស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។

❈នារសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី “កិច្ចការសភា (ជំហានទី៦)” សម្រាប់អ្នកគ្រប់គ្រងការិយាល័យ នៅសាលសិក្ខាសាលខាងជើងវិមានព្រឹទ្ធសភា។

❈នារសៀលថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យអំពីការរៀបចំ Mobile App របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ តំណាងមជ្ឈមណ្ឌលសភាអាស៊ី និងតំណាងក្រុមហ៊ុន CODE‘s DONE។

❈ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ម៉ុន ឧុន្ធា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី បានអញ្ជើញបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីការផ្តល់សេវារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាថៃ ទាក់ទងនឹងព័ត៌មានវិទ្យា ទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងការគ្រប់គ្រងធនធានមនុស្ស នៅវិមានសភាថៃ។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ គណៈកម្មការសមាគមមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃសមាគមសង្គហមន្ត្រីរាជការ នៃក្រុមនិតីប្បញ្ញត្តិ បានប្រជុំក្រោមការដឹកនាំដោយឯកឧត្តម **លី រិទ្ធី** ប្រធានសមាគមមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីពិនិត្យពិភាក្សាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារបន្ត និងបញ្ហាផ្សេងៗ នៅសាលប្រជុំពិសេសខាងក្រោមវិមានព្រឹទ្ធសភា។



❈នាថ្ងៃអាទិត្យ ទី១១ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **លី ឡេខ** នាយកខុទ្ទកាល័យអនុប្រធានទី១ព្រឹទ្ធសភា និងជាតំណាងរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យវឌ្ឍភាព នៃការកសាងកំផែងវត្ត នៅវត្តពង្ររង្សី ហៅវត្តជ្រៃម្រាក់ ស្ថិតក្នុងឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។



❈លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **អំ សុខ** ញោមបង្កើតរបស់សម្តេចព្រះពោធិវង្សកិត្តិបណ្ឌិត **អំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិរកាកោង នៅឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល។



❈នាព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ បណ្ណាល័យព្រឹទ្ធសភា សហការជាមួយនឹងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បានរៀបចំកម្មវិធីបាឋកថាស្តីពី ការឈ្វេងយល់ពីវិជ្ជាពេទ្យបុរាណចិន ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និស្សិត នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុបសរុបជាង៨០នាក់ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា៕



